# ដំណើរប្រូតត្ស សើន ដៀប នៅក្រុងប៉ារីស នាឆ្នាំ ១៩០០

ដោយបណ្ឌិតសភាចារ្យ ឃីង ហុកឌី

*នៅស្រុកសៀម អក្សរសិល្ប៍ស្ដីពីការធ្វើដំណើរជាកំណាព្យចូលក្នុងប្រភេទអក្សរសិល្ប៍* និរ៉ាត/និរាស (*ពាក្យក្លាយពីសំស្ក្រឹត* និរាស មានន័យថា « *ប្រាស ព្រាត់, និរទេស*») *។ អត្ថបទនិរាស ដើមឡើយ សម្រាប់ពោលច្រៀងពីទុក្ខព្រួយ ដោយត្រូវធ្វើដំណើរឃ្លាតឆ្ងាយទៅទី ១ ទៀត ឬឃ្លាតឆ្ងាយពីគូស្នេហ៍ឬពីអ្នកដែលជាទីស្រឡាញ់ ។ ជាដំបូង អក្សរសិល្ប៍និរាសនេះ គឺជាកំណាព្យតាក់តែងថែងពីសេចក្ដីស្នេហា*[១] *។ តែអក្សរសិល្ប៍ប្រភេទនេះ បានដូររូបរាងជាពិសេសអាស្រ័យដោយមានការវិវឌ្ឍន៍ បន្ទាប់ពីមានបេសកកម្មផ្លូវការ និងដំណើរចេញទៅបរទេស ។ ប្រភេទថ្មីនៃអក្សរសិល្ប៍និរាសនេះ បានផុសឡើងរវាងចុងសតវត្សទី ១៨ ដោយមានអត្ថបទកំណាព្យ «និរាសក្វាងទុង» ដែលនិពន្ធឡើងដោយព្រះមហានុភាពនា ឱកាសបញ្ជូនគណៈទូតទៅប្រទេសចិន ក្នុងឆ្នាំ ១៧៨១ ដើម្បីចងស្ពានមេត្រីនឹងអធិរាជគីយងឡុង* (Qianlong *១៧៣៦-១៧៩៥*) *។ ដល់ក្រោយមក មានអត្ថបទអក្សរសិល្ប៍និរាសជាបន្ត*

(១) P. Schweisguth (*Étude sur la littérature siamoise*, Paris, Imprimerie nationale, 1951, p. 90) បានឲ្យនិយមន័យប្រភេទអក្សរសិល្ប៍នេះថា « អ្នកនិពន្ធច្រៀងជាដំបូងពីសោភណ-ភាពនារីជាទីស្រឡាញ់ដែលខ្លួនបានឃ្លាតចេញ, បន្ទាប់មក វិវឌ្ឍន៍ទៅក្នុងបរិបទការធ្វើដំណើរ ។ កវីនិពន្ធពណ៌នាពីអនុស្សាវរីយ៍ដែលនៅជិតជាប់នឹងអារម្មណ៍ ដោយមានរៀបរាប់ពីទីកន្លែងនៅតាមផ្លូវហើយម្នាក់ ៗ បង្ហាញពីចិត្តគំនិតអារម្មណ៍ឆ្ពោះទៅលើគូស្នេហ៍» ។ សូមអានបន្ថែមអត្ថបទស្រាវជ្រាវ P. Schweisguth, « Les “Nirat” ou poèmes d’adieu dans la littérature siamoise », *Journal of the Siam Society*, 1950, p. 67–78 ; Manas Chitakasem, « The emergence and development of the *nirāt* genre in Thai poetry », *Journal of the Siam Society*, July, vol. 60, 2, 1972, p. 135–168; id., *The nature of* nirāt *Poetry and the Development of the Genre*, PhD, University of London, 1974 ។

*បន្ទាប់ ដើម្បីរំឭកដល់បេសកកម្មផ្លូវការនៅបរទេស ដូចជានៅចក្រភពអង់គ្លេស (១៨៥៧-១៨៥៨), នៅកាល់កុត្តា (១៨៥៩) និងហាណូយ (១៨៨៧) ហើយនិងអត្ថបទឯទៀតនៅសតវត្សទី២០*[២] ។

*មែកធាងប្រភេទអក្សរសិល្ប៍នេះ ដែលមានប្រធានបទស្ដីពីការនឹករឭកស្នេហា បានសម្រួលផ្ទៀងទៅរកការពណ៌នាលំអិតពីស្ថានការណ៍ ដែលកើតមានក្នុងរយៈពេលធ្វើដំណើរ ហើយនិងការរៀបរាប់ពីទេសភាពនិងពីប្រជារាស្ត្រ ។ មែកធាងប្រភេទអក្សរសិល្ប៍នេះ មានកំណើតនៅប្រទេសកម្ពុជាដែរ តែអត្ថរូបខុសដោយអន្ទើពីប្រភេទនិរ៉ាត*[៣]*សៀម ។ ប្រភេទអក្សរសិល្ប៍និរាសនេះ មានការរីកចម្រើននាដើមសតវត្សទី ២០ នៅកម្ពុជា ក៏ពិតមែនហើយ ជនានុជនយើងស្គាល់ខ្លះហើយក៏ដោយ តែមិនទាន់ជាប្រធានបទសិក្សាឲ្យបានជ្រៅជ្រះនៅឡើយ មិនដូចនៅស្រុកសៀមទេ ។ មកដល់បច្ចុប្បន្ននេះ យើងរកឃើញអត្ថបទកំណាព្យប្រភេទនិរាសនេះ ៤ ដែលតាក់តែងឡើង ដោយមហាមន្ត្រី នាឱកាសធ្វើដំណើរផ្លូវការក្នុងប្រទេស (មួយ) និងនៅក្រៅប្រទេស (៣)*[៤] *។ យើងបង្ហាញនៅក្នុងសិក្សាកថានេះ នូវអត្ថបទមួយ ដែលតាក់*

---

(២) Cf. Manas Chitakasem, « The emergence and development of the *nirāt* genre in Thai poetry », *Journal of the Siam Society*, July, vol. 60, 2, 1972, p. 165–168 ។

(៣) ពាក្យនេះក្លាយពីពាក្យសំស្ក្រឹត មានន័យថា « ដំណើរអស់បំណង, អស់សង្ឃឹម, ដែលអស់បំណង, ប្រាស, ឃ្លាតឆ្ងាយ », វចនានុក្រមខ្មែរ, ទំព័រ ៥១៤ ។ ពាក្យនេះមានប្រើក្នុងសិលាចារឹកតាំងពីសតវត្សទី ៧ ដែលក្លាយពីសំស្ក្រឹត « និរាស្ត ៖ និរាស, ត្រូវកំចាត់ ។ មនុស្សដែលត្រូវកំចាត់ចេញពី... », ឡុងសៀម, *វចនានុក្រមខ្មែរបុរាណ*, ភ្នំពេញ, ២០០០, ទំព័រ ៣៦៧ ។

(៤) យើងលើកតែអត្ថបទប្រភេទនិរាសជាកំណាព្យ ។ តែយើងមិនលើកអត្ថបទស្ដីពីការធ្វើដំណើរទៅបរទេស ជាពាក្យសម្រាយទេ ។ ចំពោះអត្ថបទការធ្វើដំណើរជាសម្រាយសូមអាន ៖ **ព្រះករុណាព្រះចាទសម្ដេចព្រះ ស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី ព្រះរាជដំណើរទៅក្រុងបារាំងសែស ឆ្នាំមមីអដ្ឋស័ក ត្រូវនឹងឆ្នាំបារាំង ១៩០៦** ។ និពន្ធដោយអ្នកឧកញ៉ាវាំង វរៈវៀងជ័យ អធិបតីពិភ័ក្តិស្រីង្គារ ឧត្តមក្រុមពាហុ ជួន, បោះពុម្ពដោយ មីស្លែល បូទ្វី អង់តែល្មា និង អូលីវិយេ៍រ ដឺ ប៊ែរណុង, ភ្នំពេញ, ២០០៦, ១៨៩ ទំព័រ ។ សៀវភៅនេះ បកប្រែជាភាសាបារាំងមានចំណងជើងថា ៖ Okñā Veang Thiounn, *Voyage du roi Sisowath en France,* traduit du khmer, présenté et annoté par Olivier de Bernon, Paris, Mercure de France, 2006, 259 p. ។

*តែងឡើង ដោយប្រតិភូ សើន ដៀប ក្នុងឱកាសលោកធ្វើដំណើរមកប្រទេសបារាំង នាឆ្នាំ ១៩០០ មានចំណងជើងថា* **ល្បើកលើកតាមផ្លូវនៅស្រុកបារាំងសែស នៅទីតាំងតុនៅក្រុងប៉ារីស៍** (៥) *។ ពិតមែនតែចំណងជើងឥតមានពាក្យនិរាសក៏ដោយ តែសាច់រឿងនិងរបៀបតែងនិពន្ធ មានលក្ខណៈចូលក្នុងប្រភេទ «អក្សរសិល្ប៍និរាស» នេះឯង ។*

*ជាបឋម គួរតែបង្ហាញដោយសង្ខេបត្រួសៗ ពីអក្សរសិល្ប៍ខ្មែរ ស្តីពីដំណើរសិន ។ បែបផែនអក្សរសិល្ប៍ខ្មែរប្រភេទនេះ មានកំណើតឡើងនាចុងសត-វត្សទី ១៩ ហើយបន្តមកទៀតរហូតមកដល់ទសវត្ស ១៩២០ ។ ឯកសារចាស់ជាងគេដែលយើងស្គាល់ គឺ* **និរាសហុងកុង** (៦) *គឺជាអត្ថបទកំណាព្យតាក់តែងឡើងដោយមន្ត្រីម្នាក់ឥតបញ្ចេញឈ្មោះ នៅឱកាសដែលព្រះមហាក្សត្រនរោត្តម (១៨៦៤-១៩០៤) ធ្វើរាជបេសកកម្មទៅហុងកុង, ម៉ាកកាវ, ក្វាំងទុង, ម៉ានីល នាខែកក្កដា-សីហា ឆ្នាំ ១៨៧២ ។ កំណាព្យនេះឥតមាននិយាយពីគោលដៅនៃបេសកកម្មនេះទេ ។ តែគេដឹងតាមប្រភពផ្សេងទៀតបង្ហាញថាជា «ដំណើរកំសាន្តស្វែងយល់» ក្នុងប្រទេសជិតខាង ដែលចាត់ចែងឡើងដោយលោកឧត្តមនាវីឌុយប្រេ* (Amiral Dupré *១៩០៤-១៩២៧*) (៧) *។ ស្តេចនរោត្តម ដង្ហែដោយមេបញ្ជាការទ័ពសមុទ្រ ២ នាក់ គឺលោក មូរ៉ា និងសើនេ* (Moura, Senez) (៨) *។ ព្រះអង្គគង់លើកប៉ាល់ចម្បាំង ជានាវាល្បាត*

---

(៥) យើងសរសេរតាមអក្ខរាវិរុទ្ធបច្ចុប្បន្ន ។ នេះចំណងជើងដើម ៖ ល្បើកលើកតាមផ្លូវនៅស្រុកបារាំងសែ្សនៅទីតាំងតុះនៅក្រុងប៉ារីស៍/*Voyage en France pendant l'exposition universelle de 1900 à Paris*, Paris, Imprimerie cambodgienne Plon-Nourrit, 1902, 44 p. ฯ

(៦) សាស្ត្រាស្លឹករឹតតម្កល់នៅសាលាចុងបូព៌ាប្រទេសប៉ារីស៍ ចុះលេខបញ្ជី ១៤១ មាន ៥៥ សន្លឹកចារទាំងសង្ខាង និងឯកសារសរសេរដៃលើក្រដាសខ្នាតធំ ចុះលេខ ៩ មាន ៧៦ ទំព័រ ។

(៧) ឧត្តមនាវី ឌុយប្រេ កើតនាឆ្នាំ ១៨១១ ជាអភិបាលឥណ្ឌូចិន នាឆ្នាំ ១៨៧១ ។ សូមអាន Brébion, *Dictionnaire de bio-bibliographie générale, ancienne et moderne de l'Indochine Française*, Publié après la mort de l'auteur par Antoine Cabaton, Paris, Académie des Sciences coloniales, 1935, p. 143 ฯ

(៨) Jean Moura (1827–85) était alors représentant du protectorat à Phnom Penh ; quant à V.F.E. Senez (1830–92), il avait participé à la Campagne de Chine et de

ឈ្មោះ « បួរែន » (Bourayne) [៩] ។ និរាសហុងកុងនេះ ពណ៌នាជាពិសេសពី រាជដំណើរ ដោយលំអិត ពីការទទួល ដោយមានបាញ់កាំភ្លើងធំនៅតាម កំពង់ផែនិមួយៗ ។ នៅហុងកុង ព្រះមហាក្សត្រធ្វើទស្សនកិច្ចអស់រយៈពេល ៥ ថ្ងៃ, ព្រះអង្គត្រូវបានទទួល ដោយលោកអភិបាលក្រុង ជូនព្រះអង្គទត កំសាន្តទីក្រុង មានសង្កាត់ពាណិជ្ជកម្មចិន និងសួនឧទ្យានសាធារណៈនានា ដែលមានបុប្ផារីកស្គុះស្គាយ ។

អត្ថបទកំណាព្យទី ២ ស្ដីពីរាជដំណើរទស្សនកិច្ចផ្លូវការស្ដេចព្រះ ស៊ីសុវត្ថិ នៅអង្គរ នាឆ្នាំ ១៩០៩ [១០] និពន្ធដោយរាជកវីបណ្ឌិត នាម ឧកញ៉ាសុត្តន្ត-ប្រីជា ឥន្ទ [១១] មានចំណងជើងថា **និរាសអង្គរវត្ត** [១២] បង្ហាញពីរាជ ដំណើរ តាមកប៉ាល់ទឹក ពីទីក្រុងរហូតដល់ភ្នំក្រោម (សៀមរាប), ពណ៌នា ត្រួសៗ ពីការឈប់សំចតតាមផ្លូវ ជាពិសេសនៅខេត្តបាត់ដំបង ដែលនៅទី

---

Cochinchine et, considérant que sa tâche terminé, il était sur le point de rentrer en France. Brébion, *op. cit.*, p. 269–270; 347–348. ។

(៩) Cf. Brébion, *op. cit.,* p. 282 ។ តាមរបាយការណ៍នៅគ្រប់ទិសទីស្ដេចត្រូវគេទទួលដោយឱឡារិកនិងដោយកិត្តិយស, ព្រះអង្គចាប់ព្រះទ័យយ៉ាងខ្លាំងពីទស្សនកិច្ចនេះ ។ តែតុល្យការពីដំណើរទស្សនកិច្ចបានត្រឹមតែជ្រើសរើសសិល្បករមួយក្រុមពីស្រុកម៉ានីលប៉ុណ្ណោះ ... ។ Ch. Meyer, *La vie quotidienne des Français en Indochine*, Paris, Hachette, 1985, p. 119 ។

(១០) កាល ២ ឆ្នាំមុននោះ ក្រោយពីសន្ធិសញ្ញារវាងបារាំងនិងសៀម, ប្រទេសកម្ពុជាបានទទួលត្រឡប់មកវិញនូវខេត្តបាត់ដំបង, សៀមរាបនិងស៊ីសុផុនដែលសៀមបានផ្ដាច់យកនាឆ្នាំ ១៧៩៤ ។ សូមអាន Brébion, *op. cit.,* p. 353 ។

(១១) សូមអាន ឃីង ហុកឌី, *អក្សរសិល្ប៍ខ្មែរសតវត្សទី ២០ – ការនិពន្ធនិងកម្រងអត្ថបទ*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧, ទំព័រ ៧១ –៧៨ ។

(១២) បោះពុម្ពលើកទី ១ ក្នុងទស្សនាវដ្ដី *កម្ពុជសុរិយា* លេខ៧, ៨, ៩, ឆ្នាំ ១៩៣៤ ហើយក្រោយមក ប្រមូលបោះពុម្ពជាសៀវភៅ នៅពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៩ ។ សូមអាន Brébion, *op. cit.,* p. 353 សរសេរពីរាជដំណើរនេះដែរថា ស្ដេចបានយាងទៅអង្គរនាឆ្នាំ ១៩០៩, រាជដំណើរនេះផ្ដល់ឲ្យមានប្រារព្ធពិធីបុណ្យយ៉ាងធំ ដោយមានពួកអឺរ៉ុបមកចូលរួមជាច្រើន ៖ Le roi « se rendit à Angkor en 1909, voyage qui donna lieu à de grandes fêtes, auxquelles assistèrent de nombreux Européens » ។

*នោះ ចៅហ្វាយខេត្តនិងអធិការមកទទួលព្រះអង្គ*[១៣] *។ រាជករីនិពន្ធណ៌នាពីការទស្សនាអង្គរ ដង្ហែពន្យល់ ដោយលោកអភិរក្សប្រាសាទ នាម គំម៉ៃយ* (Commailles)[១៤] *ស្តីពីសោភណភាពចម្លាក់និងប្រាង្គប្រាសាទ ហើយរំឭកពីប្រវត្តិសាស្ត្រទាក់ទងនឹងរឿងព្រេង ពីការសាងសង់ប្រាសាទអង្គរវត្ត ដោយស្តេចព្រះកេតុមាលា ។ រាជដំណើរត្រឡប់មកវិញ, ករីនិពន្ធបានរៀបរាប់ពីការកាត់តាមកំពង់ស្វាយឈប់សម្រាក ។*

*អត្ថបទពាក្យកាព្យស្តីពីដំណើរមួយទៀត ដែលមានកាលបរិច្ឆេទថ្មីជាងគេ គឺជាស្នាដៃលោកអ្នកឧកញ៉ាប្រសើរសុរិសក្តិ៍ អ៊ុក ជាចាងហ្វាងរាជការក្នុងព្រះបរមរាជវាំង តែងតាំងពីកាលនៅទីជាឧកញ៉ាស្រីធម្មាធិរាជ ក្លួយសេនាបតីក្រសួងព្រះបរមរាជវាំង ព្រះឃ្លាំង និងក្បាច់រចនា ។ ស្នាដៃនេះមានចំណងជើងថា* **អំពីដំណើរទៅក្រុងបារាំងសេស កាលពីឆ្នាំ ១៩២៣** *គឺជាទស្សនកិច្ចផ្លូវការ នាពេលពិព័រណ៍អាណានិគមនៅម៉ារសីយ* (Marseille)[១៥] *។ អត្ថបទដំណើរទៅក្រុងបារាំងសេសនេះ ប្រារព្ធឡើងខាងដើម ដោយព្រះរាជប្រកាស ថ្ងៃ ២៥ មីនា ១៩២២ ចុះព្រះរាជហត្ថលេខាព្រះស៊ីសុវត្ថិនិងលោកតំណាងរដ្ឋាភិបាលបារាំងជាន់ខ្ពស់ បូដួអាំង* (Baudouin, résident supérieur) *អនុញ្ញាត*

---

(១៣) រាជករី ឥន្ទ បានពន្យល់បន្ថែម ពីនាមទីកន្លែង តាមបែបនិរុត្តវិជ្ជា ជាពិសេស នាម « សៀមរាប » ជាទីកន្លែង ដែលខ្មែរយើងបានវាយបង្ក្រាបសៀមឲ្យរាប ។

(១៤) Jean Commailles (1868–1916) បានទទួលដំណែងជាអភិរក្សប្រាសាទអង្គរ នាឆ្នាំ ១៩០៨ ។ លោកបានសរសេរសៀវភៅមួយសំខាន់ ៖ *Guide aux ruines d'Angkor*, Paris, Hachette, 1912 ; cf. Brébion, *op. cit.*, p. 88 ។

(១៥) *អំពីដំណើរទៅក្រុងបារាំងសេសកាលពីឆ្នាំ ១៩២៣*, ភ្នំពេញ, រាជបណ្ណាល័យកម្ពុជា, ១៩៣១, ១៨៣ ទំព័រ ។ នៅក្រុងបារីស៍ តាំងពីចុងសតវត្សទី ១៩ មក លោកសង្ឃកាតុលិក គ្តេដុង (Guesdon) បានបង្កើតអក្សរពុម្ព ហើយបានបោះពុម្ពផ្សាយអត្ថបទអក្សរសិល្ប៍ខ្មែរជាច្រើន មាន រឿងព្រេង, រឿងល្បែង, ច្បាប់ផ្សេង ៗ និងសៀវភៅធម៌កាតុលិក ។ល។ Cf. L. Feer, « Les nouveaux caractères cambogiens de l'Imprimerie Nationale », *Mémoires de la Société Académique Indo-chinoise de France I (année 1877–78)*, Paris,1879, p. 270–272 ។

ឲ្យក្រុមសិល្បៈរាជទ្រព្យទៅសម្ដែងនៅក្រុងធំៗ នៅប្រទេសបារាំង[១៦] ។ កវីនិពន្ធរូបនេះបានរំឭកថា លោកបានមកប្រទេសបារាំងម្ដងហើយ នាឆ្នាំ ១៩០៦[១៧] ដើម្បីដង្ហែព្រះបាទស៊ីសុវត្ថិ[១៨] ។ លោកបានបង្ហាញដំណើរចេញពីទីក្រុង កាត់តាមសឹង្ហប៉ូរ (សិង្ហបូរី), ម៉ាឡាយូ (ម៉ាឡេស៊ី), កូឡុម្បូ (ស្រីលង្កា), អ៊ីតាលី រួចមកដល់ក្រុងទូឡុង ហើយមកដល់ម៉ារសីយ ។ បន្ទាប់លោកឧកញ៉ាវ៉ាយវ៉ាប់ពីការទទួល ដោយលោក អាលប៊ែរ សារ៉ូ (Albert Sarraut) ជាអតីតទេសាភិបាលឥណ្ឌូចិន ។ ទស្សនកិច្ចនិងការសម្រាករបស់លោកនៅប៉ារីស ក្នុងរយៈពេលតាំងតុនេះ នាំឲ្យលោកអាចបានទស្សនាប្រាង្គប្រាសាទ

---

(១៦) ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ (...) បានទ្រង់យល់សេចក្ដី ដែលកុងសីយសេនាបតីបានជំនុំជាអាចិន្ត្រៃ (...) ឆ្នាំ ១៩២២ ។

បានទ្រង់យល់សេចក្ដី ដែលទ្រង់បានជំនុំ ព្រមនឹងម៉ុងស៊ីយ៉ើរឡឺរេស៊ីដង្គសុប៉េរីយ៉ើរ ។

ត្រាសបង្គាប់ ដូចមានសេចក្ដីខាងក្រោយនេះ

ប្រការ ១ – ទ្រង់ព្រះមេត្តាប្រោសឧកញ្ញាស្រីធម្មាធិរាជ (អ៊ុក) ភូវឈ្នួយសេនាបតី ក្រសួងព្រះបរមរាជវាំង ព្រះឃ្លាំង នឹងរចនា ក្រុងកម្ពុជាធិបតី ឲ្យត្រួតលើក្រុំល្ខោនព្រះរាជទ្រព្យ ក្នុងបរមរាជវាំង ត្រូវឲ្យឧកញ្ញាស្រីធម្មាធិរាជនាំក្រុំល្ខោននេះ ទៅក្នុងក្រុងបារាំងសែស នឹងរាំក្នុងបុណ្យតាំងតុះឥស្បូស៊ីស្យុង ស្រុកម៉ារសី រាជការដែលធ្វើនេះ កំណត់រវាង ៦ ខែ គឺ ២ ខែទៅវិញទៅមកវិញ រវាង ៤ ខែនៅក្នុងក្រុងបារាំងសែស ។» **ដំណើរទៅក្រុងបារាំងសែស**, ទំព័រ ១ ។

(១៧) សូមអានអត្ថបទពាក្យរាយ **ព្រះករុណាព្រះបាទសម្ដេចព្រះ ស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី ព្រះរាជដំណើរទៅក្រុងបារាំងសែស ឆ្នាំមមីអដ្ឋស័ក ត្រូវនឹងឆ្នាំបារាំង** ១៩០៦ ។ និពន្ធដោយអ្នកឧកញ៉ាវាំងវរៈវៀងជ័យ អធិបតីពិភ័ក្តិស្រឹង្គារ ឧត្តមក្រុមពាហុ ជួន, បោះពុម្ពដោយ មីស្ហែល ឫទ្ធី អង់តែល្ម និង អូលីវិយ៉េរ៍ ដឺ ប៊ែរណុង, ភ្នំពេញ, ២០០៦, ១៨៩ ទំព័រ ។ សូមអានទំព័រ ៩ ចារថា ៖ « ឧកញ៉ាប្រីជាសោភ័ណ (អ៊ុក) ស្មៀនប្រែភាសាថ្វាយ ។»

(១៨) « កាលនោះចក្រ (...)  ពង្សទ្រង់យសខ្ពស់បារមី
ប្រជុំរាជសេនាបតី  ឲ្យចាត់មន្ត្រីក្រសួងវាំង ។
គឺអ្នកឧកញ្ញាស្រីធម្មា  ព្រោះមានវិជ្ជាចេះដឹងខ្លាំង
ចេះគ្រប់ភាសាខ្មែរបារាំង  មឹនមានភាន់ភាំងកន្លែងណា ។
ធ្លាប់បានហែរហមព្រះចមច័ក្រ  វារកន្លងជាអតីតា
ឆ្នាំ ១ ពាន់ ៩ រយប្រាំមួយណា  ក្សត្រាយាងទៅប៉ារីសថាន ។»

(អក្ខរាវិរុទ្ធដើម) **អំពីដំណើរទៅក្រុងបារាំងសែសកាលពីឆ្នាំ ១៩២៣**, ទំព័រ ១២ ។

នានា និងបានជួបបុត្រាលោក នាម «អ៊ុក ប៊ុន» ដែលបានមកសិក្សានៅសាលានាយទាហាន នៅប្រទេសអាល្ហឺម៉ង់ ។ លោកបានជួបអធិរាជ ខៃ ឌិញ (Khai Dinh, ១៩១៦-១៩២៥, បានប្រទានឥស្សរិយយសដល់លោកនិងសិល្បករទាំងឡាយ) និងអ្នកមុខអ្នកការនានា ។ នៅទីបញ្ចប់ លោកពណ៌នាពីដំណើរត្រឡប់ទៅនគរវិញ ដោយកាត់តាមកំពង់ផែ «សៃអ៊ីត» តាមនាវានាំសារ ក្រោយពីបានទុកកូនប្រុសប្អូនម្នាក់ទៀត នាម «អ៊ុក ប៊ុនចន» ឲ្យនៅសិក្សាក្នុង «សាលាជាន់ខ្ពស់ពាណិជ្ជកម្ម» នៅប្រទេសបារាំង (១៩) ។

អត្ថបទកំណាព្យលោក សើន ដៀប ដែលយើងយកមកសិក្សាវិភាគនេះ បានទទួលប្រជាប្រិយភាពនៅពេលនោះ ព្រោះបានបោះពុម្ពផ្សាយយ៉ាងតិច ២ ដង គឺលើកទី ១ នាឆ្នាំ ១៩០១ បោះផ្សាយតាមបច្ចេកទេសពុម្ពថ្ម (lithographie) តែយើងរកសំណៅមិនឃើញ ហើយបោះពុម្ពលើកទី ២ នាឆ្នាំ ១៩០២ នៅក្រុងប៉ារីស នៅគ្រឹះស្ថាន ប្លុង-នួរី (Plon-Nourrit, 8 rue Garancière) ដោយការផ្តួចផ្តើមពីលោកសង្ឃកាតុលិក គ្ហេដុង (Abbé J. Guesdon) ដែលជាអ្នកបង្កើតអក្សរពុម្ពខ្មែរ ។ សៀវភៅ **ល្បើកតាមផ្លូវនៅស្រុកបារាំងសែស ...** មានផែនទីជាខ្មែរ បង្ហាញពីផ្លូវទឹក ពីព្រៃនគរហូតដល់ម៉ារសី និងរូបភាពចំនួន ១៤ ស្តីពីទេសភាពនិងប្រាង្គប្រាសាទនៅប្រទេសបារាំង ។

មុននិងសិក្សាវិភាគកំណាព្យនេះ, យើងគួរលើកជាបឋមពីពត៌មានខ្លះៗ លើកវីនិពន្ធនេះសិន ។

## មន្ត្រីរាជការនិពន្ធ សើន ដៀប

កើតរវាងឆ្នាំ ១៨៥០ នៅកម្ពុជាក្រោម តំបន់ត្រាវិញឬស្រុកទ្រាំង, លោកបានរៀនភាសាបារាំងជាមួយនឹងលោកអ្នកបួសកាតុលិក ក្រុមបេសកកម្មបរទេស ។

---

(១៩) « កាលដែលជិតចេញដំណើរមក លែលកនាំបុត្រប្រុសមួយអ្នក
ទៅជូនរាជការក្លាសីល្បសក្តិ ទុកដាក់ឲ្យប្រិតប្រៀនវិជ្ជា ។
ឈ្មោះអ៊ុកប៊ុនចនជាកុមារ កបរឹកបញ្ញាមុះហិមា
ក្នុងសាលាជំនួយធំសោភា នៅនាក្រុងព្រៃប្រពៃថាន ។ »
(អក្ខរាវិរុទ្ធដើម) អំពីដំណើរទៅក្រុងបារាំងសែសកាលពីឆ្នាំ ១៩២៣, ទំព័រ ១៣៦ ។

លោកបានទទួលដំណែងជាអ្នកបកប្រែភាសា នៅរវាងឆ្នាំ ១៨៧០ ក្នុងរដ្ឋអំណាចអាណានិគមបារាំងសេស នៅប្រទេសកម្ពុជា ហើយលោកមានតួនាទីសំខាន់ទាំងផ្នែកនយោបាយនិងស្រាវជ្រាវ នៅទសវត្សចុងក្រោយនៃសតវត្សទី ១៩ ។ ចាប់ពីឆ្នាំ ១៨៦៣, ព្រះរាជាណាចក្រកម្ពុជានៅក្រោមអាណាព្យាបាលប្រទេសបារាំងសេស ហើយខេត្តនានានៅយៀកណាមខាងត្បូងសព្វថ្ងៃ (មាត់ជ្រូក, ស្រុកទ្រាំង, ព្រះត្រពាំង..) នៅក្នុងការគ្រប់គ្រងរដ្ឋអំណាចកូសាំងស៊ីនជាហេតុឲ្យមានទំនាស់វិបត្តរវាងហ្លួង នរោត្តម និងរដ្ឋអំណាចបារាំង ៗ បានបង្ខិតបង្ខំស្ដេចឲ្យចុះហត្ថលេខាលើសន្ធិសញ្ញានានា បណ្ដាលឲ្យមានការបះបោរជាទូទៅនៅឆ្នាំ ១៨៨៥-១៨៨៦ ។ នៅពេលដែលបារាំងបានបង្ខំឲ្យហ្លួង នរោត្តម ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានា, បារាំងបានចាប់បង្ខាំងលោកសើន ដៀប ទុក ដើម្បីកុំឲ្យបកប្រែជាភាសាខ្មែរទូលហ្លួងពីសេចក្ដីនៃអនុសញ្ញាថ្មីនេះ[(២០)] ។ ក្នុងតួនាទីលោកជាអ្នកបកប្រែភាសា, លោកបានជួយសរសេរវចនានុក្រមខ្មែរ-បារាំង[(២១)] និងកិច្ចស្រាវជ្រាវនានារបស់លោក អែម៉ូនីញេ[(២២)] ជាដើម ។ នៅចុងសតវត្សទី ១៩ លោកបានទទួលដំណែងជា « ហៀន»

(២០) Cf. Adh. Leclère, *Histoire du Cambodge*, Paris, Geuthner, 1914, p. 465–466 : « Le roi ne comprenait pas que s’il avait tenu les promesses qu’il avait faites en 1877, mais dont malheureusement on ne lui avait plus guère parlé depuis, il n’avait pas été mis en demeure de signer les actes de 1884 ; il comprenait encore moins qu’il n’avait rien à perdre de cette nouvelle convention (...). Nos représentants du Protectorat avaient vécu près de lui comme des consuls, non comme des résidents chargés par la France de donner l’impulsion. De retour à l’hotel du Protectorat, le gouverneur donna l’ordre de préparer les arrêtés nécessaires et **l’interprète Diep,** aujourd’hui ministre de la batterie ou de la marine, fut séquestré afin qu’il ne pût communiquer avec l’extérieur et mis à la besogne. L’œuvre qui n’avait pas été préparée, réfléchie, fut maladroite et sans avenir possible ; elle se sentait de la hâte un peu ridicule avec laquelle tout ce qu’on imaginait était fait. » ។

(២១) E. Aymonier, *Dictionnaire khmêr-français*, Saïgon, 1878 (autographié par Son Diêp) ។

(២២) E. Aymonier, *Textes khmers*, Saïgon, 1878 (autographié) ។

(ពាក្យឃ្លួន មានងារស្មើនឹងចៅហ្វាយស្រុក) ថ្នាក់ទី ១ នៅស្រុកទ្រាំង នៅកម្ពុជាក្រោម ហើយលោកបានជួយលោកសង្ឃកាតូលិក គេ្កាដុង[២៣] តែងវចនានុក្រមបារាំង-ខ្មែរ និងខ្មែរ-បារាំង ។ ក្នុងរាជ្យហ្លួង ស៊ីសុវត្ថិ (១៩០៤-១៩២៧) លោកទទួលការតែងតាំងជាមហាមន្ត្រីចតុស្តម្ភ ងារជាក្រឡាហោម ។ យើងឥតដឹងកាលបរិច្ឆេទនៃមរណកាលលោកទេ តែយើងស្មានថា លោកអនិច្ចកម្មរវាងចុងរាជ្យស្តេច ស៊ីសុវត្ថិ ។ បុត្រីលោកម្នាក់[២៤] បានជាស្នំបុត្រាហ្លួង មុនីវង្ស ព្រះនាម ស៊ីសុវត្ថិ មុនីពង្ស ហើយចៅស្រីលោកម្នាក់ នាម ស៊ីសុវត្ថិ សុវេទវង្ស (១៩៤៥-១៩៩៤) ហៅ ឡូឡា ឬ លីដា បានទទួលតំណែងជាតំណាងរាស្ត្រ ពីឆ្នាំ ១៩៧៩ ដល់ ១៩៩១ ក្រោមរដ្ឋាភិបាលកុម្មុយនិស្ត ដែលទទួលឥទ្ធិពលយៀកណាម[២៥] ។

## ទំនាក់ទំនងលើការធ្វើដំណើរ

កវីបានបង្ហាញនៅលើសេចក្តីផ្តើមពីអត្តរូបកំណាព្យលោក គឺជាកំណាព្យ « ពាក្យ ៧ » ក្នុងមួយវគ្គ មាន ៤ ឃ្លា បានសេចក្តីថា ទាំងអស់មាន ៧០៤ ឃ្លា សរុបក្នុង ១៧៦ វគ្គ ៖

« អត្តិតេកែគិតអត្តិតា　　　　សត្តរោហារឃ្លោរចតុះ
ចិន្តាប្រាជ្ញាថ្លាផុរផុស់　　　　ឆ្លាតឆ្លុះលុះសព់គ្រប់ប្រការ ។[២៦] »

(២៣) J. Guesdon ។

(២៤) បុត្រីលោក នាម សើន នារី ជាស្នំបុត្រាហ្លួងមុនីវង្ស ព្រះនាម ស៊ីសុវត្ថិ មុនីពង្ស មានបុត្រី ២ អង្គ ៖ សុវេទវង្ស ហៅ ឡូឡា ឬ លីដា (១៩៤៥ –១៩៩៤) និង ពង្សនារី (១៩៤៧) ។

(២៥) Cf. *L'Humanité*, vendredi 14 octobre 1994 ; Radio-France Internationale (section cambodgienne), jeudi 13 octobre 1994 ។

(២៦) យើងគោរពអក្ខរាវិរុទ្ធកវីនិពន្ធនៅដើមសតវត្សទី ២០ ដែលមិនទាន់វចនានុក្រមផ្លូវការប្រើប្រាស់នៅឡើយទេ ។ សរសេរតាមអក្ខរាវិរុទ្ធទំនើប ៖

« អតីតេកែគិតអតិតា　　　　សត្តរោហារឃ្លោចតុ
ចិន្តាប្រាជ្ញាថ្លាផុលផុស　　　　ឆ្លាតឆ្លុះលុះសព្វគ្រប់ប្រការ ។ »

*ដើម្បីឲ្យស្របទៅតាមប្រភេទអក្សរសិល្ប៍ទំនៀម លោកបានបង្ហាញនាម និងងារសក្តិលោក ហើយបានសូមពីអ្នកអាន ដែលជាអ្នកប្រាជ្ញ ឲ្យជួយកែកំណាព្យលោក បើមានតក់កន្ទេងណាមួយ ព្រោះលោកទើបតែនឹងរៀនតែងចងក្រងជាដំបូង ទុកជាកេរតំណាទៅមុខទៀតប៉ុណ្ណោះ ៖*

«អហំឬនាមអញខ្ញុំនេះ សេិន ដៀព ត្រេះរេះជាកព្យា
នីទ្មានថ្លាថ្លែងតែងកាលគ្រា វេលាវាជ្ការប្រេិអញខ្ញុំ
ទៅមេិលតាំតុះនៅក្រៃក្រុង បារីស៍អសុជុងខ្ពុងឪដំម
ខ្ញុំជាទ្រិ្យហៀនរៀនបន្សំម ទាល់ហេិ្យប្រិ៊ងខំមតែងសាច់ក្តី ។
កាព្យល្បេិកលេិកល្បាយពាកពេជ ពុំស្រួលលេច់ត្រេច់ល្បាច់ល្បេិកថ្មី
ពាកខ្ញុំពុំខ្ពស់ក្បោះសំម្តី សេច់ក្តីជួនឆ្គងហ្មុងសៅដៅ ។
ទុំនុក់ចងទុកជាទុំម្នង ទោះខុសលោះឆ្គងពាកពេ់ជនៅ
សូមលោក្យឯណាប្រាជ្ញា៉ជ្រៅ ដំម្រង់ប្រដៅកុំនិន្ទា ។
កុំសេិចតេះដៀលដល់ខ្លួនខ្ញុំ ទាល់ហេិ្យខាសខំមផ្សំមវាច្ចារ
ទុកត៍ដំម្កល្ខឲ្យយូយា ឯក្រោយបានជាការដំណឹង ។[២៧]»

*ល្បើកដំណើរនេះ គឺហាក់ដូចជាកំណត់ហេតុក្នុងកូនសៀវភៅ ស្តីពីការធ្វើដំណើរ ជាកំណាព្យ បង្ហាញយ៉ាងលំអិតពីដំណើរទៅតាមផ្លូវសមុទ្រ និងការស្នាក់នៅប្រទេសបារាំង, តែពុំមានរៀបរាប់ពីដំណើរត្រឡប់មកប្រទេសវិញទេ ។ យើងនឹងបង្ហាញល្បើកនេះជាបែបសង្ខេប តាមលំដាប់ការពិពណ៌នា ដើម្បីគោរពចង្វាក់ហូរហែក្នុងផ្ទៃដំណើរផ្លូវទឹក ដោយបន្ថែមចំណងជើងតូចៗ នៃជំពូកនិមួយៗ ហើយលើកវគ្គកំណាព្យខ្លះៗ ជាគោលអំណាង ដើម្បីឲ្យអ្នកអានយល់ជម្រៅអត្ថបទ ។*

*ជាបឋម ផ្តើមពីទំនាក់ទំនង ៖*

«ថ្ងៃចន្ទ ៣ រោជខែស្រាពជាក់ ឆ្នាំជូតទោស័ក្ខរាជបាន
១៩០០ ខ្ញុំច៍ថ្កា៉ន ថ្ងៃអង្គាក៏បានដលព្រៃន៍គរ ។
ទ្បើងទៅគុំនាព់មេទាព់ធំម ស្តាប់អសជុំនុំដៀ្យសាទរ

---

(២៧) យើងរក្សាអក្ខរាវិរុទ្ធដើម ទុកឲ្យអ្នកអានយល់ពីអក្ខរាវិរុទ្ធនៅដើមសតវត្សទី ២០ មុនកំណើតវចនានុក្រមពុទ្ធសាសនបណ្ឌិត្យ ។

ដលថ្ងៃសៅរ៍ខ្មីយបរ          ទ្បើងរត្នសែះបរចុះភេត្រា ។
ថ្ងៃសៅ ៨ រោជខែស្រាពជាក់          ឆ្នាំមជូតទោស័ក្សនីខ្សត្រា
អរុនរុងត្រចង់រុងជ្រះថ្លា          វីហ៉ាស្រេឡះជ្រះក្រឡុង ។
ភេត្រាច្វាកចេញពីព្រៃន៍គរ          សាប់កន្ទែខ្វរពុំបង្អង
បេិកតាមនាទីលឿនស្លៅស្លុង          ស្វរីយ៍ពេញរុងមោងប្រាំម្បួន ។
ដលស្រម៉ុទក្រៅហៅវីវេក          ឃេិញទិកនឹងមេឃរ៍លែកផ្ទួន
សាប់ស្វឈ្វូឆទិរ្សទាំ ៨          ព្រះញ្យបក់ជូនរំភេីជ្ជាត ។ (...)
រសៀលមោងប្រាំមេិលយលភ្នំម          ស្កិមស្កែទុង្គុមក្នុងធារា
លេិភ្នំមមេិលមានដេិមព្រិក្ស្យា          ថ្មជាស៍ ៗ ដេ្យកន្លែង ។
ទីនោះហៅជាកោះត្រឡាច (២៨)          រ៍លែកបោកបាចមុគ្វរស្វែង
សន្ទឹកសាបឈ្វូរស្វូរគ្រឹមគ្រែង          ជុំលសាធំមទែងឥតគុន្នា ។ (២៩) »

(២៨) កោះត្រឡាច ជាអតីតដែនដីខ្មែរ ។ ជំនាន់អាណានិគមបារាំង, អាជ្ញាធរបារាំងបានធ្វើគុក យ៉ាងធំ ១ ដើម្បីដាក់ទោសអ្នកតស៊ូជនជាតិខ្មែរ, យួន, លាវ ដែលតស៊ូរំដោះជាតិចេញពីនឹម អាណានិគម ។ សូមអានសៀវភៅ ប៊ុណ្ណចន្ទ-ម៉ុល, គុកកងយោធាយ, ភ្នំពេញ, ១៩៧១, ២៧១ ទំព័រ ។ រិន គីម, **អ្នកទោសកោះត្រឡាច**, ប្រលោមលោក, ភ្នំពេញ, ១៩៧២, ២ ភាគ ។

(២៩) សើន ដៀប, ទំព័រ ៧ –៨ ។ កែតាមអក្ខរាវិរុទ្ធទំនើប ៖

« ថ្ងៃចន្ទ ៣ រោចខែស្រាពណ៍ជាក់          ឆ្នាំជូតទោស័ក(សក)រាជបាន
១៩០០ ខ្ញុំចរថ្កាន          ថ្ងៃអង្គារក៏បានដល់ព្រៃនគរ ។
ឡើងទៅគំនាប់មេទ័ពធំ          ស្តាប់អស់ជំនុំដោយសាទរ
ដល់ថ្ងៃសៅរ៍ខ្មីបរវ          ឡើងរថសេះបរចុះភេត្រា ។
ថ្ងៃសៅរ៍ ៨ រោចខែស្រាពណ៍ជាក់          ឆ្នាំជូតទោស័កនក្សត្រា
អរុណរង់ត្រចង់រង់ជ្រះថ្លា          វេហាស្រឡះជ្រះក្រឡង់ ។
ភេត្រាចាកចេញពីព្រៃនគរ          ស័ព្ទកញ្ចែខ្វរពុំបង្អង់
បើកតាមនទីលឿនស្លៅស្លុង          សូរិយពេញវង់ម៉ោងប្រាំបួន ។
ដល់សមុទ្រក្រៅហៅវិវេក          ឃើញទឹកនិងមេឃរលេកផ្ទួន
ស័ព្ទសូរឈ្វេឆរទិសទាំង ៤          ព្រះពាយបក់ជូនរំភើយជាតិ ។
(...)
រសៀលម៉ោងប្រាំមើលយល់ភ្នំ          ស្ដឹមស្កែទង្គុំក្នុងធារា
លើភ្នំមើលមានដើមព្រឹក្សា          ថ្មដាស ៗ ដោយកន្លែង ។
ទីនោះហៅជាកោះត្រឡាច          រលេកបោកបាចមុខគួរស្វែង
សន្ទឹកស័ព្ទឈ្វូសូរគ្រឹមគ្រែង          ជលសាធំទែងឥតគណនា ។ »

*(គោរពអក្ខរាវិរុទ្ធដើម)* ។

## ការឆ្លងកាត់មហាសាគរ

*លោក សើន ដៀប បង្ហាញប្រាប់ថា កប៉ាល់បើកបរអស់ ១ យប់ ២ ថ្ងៃ បានទៅដល់សិង្ហបូរីចូលចត (វគ្គទី ១៨) ហើយឃើញអ្នកជំនួញ, បារាំង, ហុឡង់, ឥណ្ឌា, ចិនគួយតាំង និងកប៉ាល់ឯទៀតៗ និងឃើញក្មេងជ្វាចុះទូកច្រៀងសើចលេង ៖*

«ជួបចូលសន្ធីយារាត្រីស្ងាត    ភេត្រាបេិកកាតត្រេចសំម្តៅ
ពីយុពម្ស្យថ្ងៃពីនោះទៅ    ដលស្រុក ១ ហៅសង្គពួរ៉ា ។
មេិលឃេិញពីនាស្យឆ្ងាស្យសន្លិម    ប្រិម ៗ ចំហុតផុតនេត្រា
មោងប្រាំម្បីចូលដលដែនភារា    នាវ្វារាចតប្រពមាត់ច្រ្ទាង ។
មេិលមានឈ្មួញឆ្ងាយច្វាយល័លក    វទេះគ័គុកមានបារាំង្ស
លន្ទាជ្វាខ្លីងចិន្តគួយតាំង    នាវីចតច្រាំងច្រេិនត្រៀបត្រា ។
ក្មេងជ្វាះម្មីម្នាចុះទូកអុំម    ជ្រៀងសេិចបន្សំមតាមភាសា
ដលហេិ្យអបផ្ទាបខាងភេត្រា    ស្រែកថាអាឡ្យាមារត្រូហ៊ឹងស៉ាន ។[៣០]»

*(វគ្គទី ១៩-២១, យើងរក្សាអក្ខរាវិរុទ្ធដើម)* ។

*កវីនិពន្ធពណ៌នាត្រួសៗ ពីទេសភាពនៅសិង្ហបូរី មានភ្នំព្រឹក្សាដុះសព្វសុះខ្ពស់យោនយានលើកំពូលបព្វតា ពពកទ្រាន មើលមានផ្សែងផ្សព្វត្រឡប់ពេញ, មានផ្លូវខ្វាត់ខ្វែងតែងយ៉ាងស្អាត, ឈ្មួញខ្មីឃ្មាតសង្វាតទិញទំនិញគ្រប់*

---

(៣០) កែតាមអក្ខរាវិរុទ្ធទំនើប ៖

« ជួបចូលសន្ធិយារាត្រីស្ងាត់    ភេត្រាបើកកាត់ត្រេចសំដៅ
ពីយប់មួយថ្ងៃពីរនោះទៅ    ដល់ស្រុក ១ ហៅសឹង្គពួរ៉ា ។
មើលឃើញពីនាយឆ្ងាយសន្លឹម    ប្រិម ៗ ចំហុតផុតនេត្រា
ម៉ោងប្រាំបីចូលដល់ដែនភារា    នាវារាចតប្របមាត់ច្រាំង ។
មើលមានឈ្មួញឆ្ងាយចាយលលក់    រទេះគគុកមានបារាំង
លន្ទា ជ្វា ក្លិង្គ ចិនគួយតាំង    នាវីចតច្រាំងច្រើនត្រៀបត្រា ។
ក្មេងជ្វាម្មីម្នាចុះទូកអុំ    ច្រៀងសើចបន្សំតាមភាសា
ដល់ហើយអបផ្ទាប់ខាងភេត្រា    ស្រែកថាអាឡ្យាមារទ្រហឹងស៊ាន ។»

*យ៉ាង, រទេះសេះបរពាសពេញ និងផ្ទះថ្មមានថ្នាក់ជាន់ទំនើបបែបនៅអឺរ៉ុប ។ ក្រៅក្រុង, កវីសង្កេតឃើញពួកជ្វានៅជាក្រុម ដូចពួកជ្វានៅខេត្តមាត់ជ្រូក*[៣១] *ដែលមានរបររកស៊ីតាមផ្លូវទឹកនិងផ្លូវគោក ៖*

« ជ្វាខ្លះនាំសេករែកទៅលក  ខ្លះរែកត្លុំមកុកលកស័ត្វា
សេកសោមបន្ទិតសត្វសារិកា  ន័រ្យិស័ក្ខណា[៣២] សោតសិងមាន ។»

*កវីបានកត់សម្គាល់ថា ពួកអង់គ្លេសមានប្រដាប់អាវុធទំនើប ៗ ច្រើន ហើយតាំងទីនៅលើភ្នំ ដើម្បីត្រួតពិនិត្យនិងយាមល្បាតក្រុង ដែលពីដើមមកជាដែនដីជ្វា ហើយលោកបានគូសបញ្ជាក់ថែមថា ៖*

« សង្កាសបូរីដីដែនជ្វា  ពីដេិមមានមហាខ្សត្រធិប្តី
សោ្យរាជគ្រុបគ្រងក្នុងបូរី  លន្ទាចាត់ខ្មីផុតវង្សា ។[៣៣] »

*(វគ្គ ២២-៣១) ។*

*កវីនិពន្ធពណ៌នាបន្តទៅទៀត ពីដំណើរតាមបណ្ដោយស្ទូម៉ាត្រា ៖*

« ចេញពីសង្កស់បូរ៉ុនោះ  ជុំពោះសង្ខាងមេិលមានភ្នំ
ព្រិក្សាបុព្តាខ្មៅទុង្គុម  ស្ទូមុាត្រាកោះធំមសិងស្រុក្កជ្វា ។
កោះនោះនៅជាខាងឆ្វេងដៃ  ឆ្ងាយពន់ពេក្យក្រៃឥតគុន្នា
សន្លឹម់ប្រិមប្រិមក្នុងជុលសា  បេិកពីទេវ្ហាផុតចេញទៅ ។[៣៤] »

*(វគ្គ ៣៣-៣៤) ។*

---

(៣១) ជាដែនដីខ្មែរពីបុរាណ នៅកម្ពុជាក្រោមសព្វថ្ងៃ ។

(៣២) នោរី គឺជាសត្វសេកមួយប្រភេទ ។ កំណែតាមអក្ខរាវិរុទ្ធទំនើប ៖ « ជ្វាខ្លះនាំសេករែកទៅលក់ ខ្លះរែកត្លុំកុកលក់សត្វា សេកសោមបណ្ឌិតសារិកា នោរីសកុណាសោតសឹងមាន » (វគ្គ ២៣) ។

(៣៣) កំណែតាមអក្ខរាវិរុទ្ធទំនើប ៖ « សិង្ហបុរីដីដែនជ្វា ពីដើមមានមហាក្សត្រធិបតី សោយរាជ្យគ្រប់គ្រងក្នុងបុរី លន្ទាចាត់ខ្មីផុតវង្សា » ។ បានសេចក្តីថា សិង្ហបុរីនេះ ពីដើមជាដែនដីជ្វា មានស្ដេចសោយរាជ្យ ហើយត្រូវពួកហូឡង់ដេ (លន្ទា) សម្លាប់ផុតពូជពង្ស ។

(៣៤) សរសេរតាមអក្ខរាវិរុទ្ធទំនើប ៖ « ចេញពីសិង្ហបូរីនោះ ចំពោះសង្ខាងមើលមានភ្នំ ព្រឹក្សាបព្វតាខ្មៅទង្គុំ ស្ទូម៉ាត្រាកោះធំសឹងស្រុកជ្វា ។ កោះនោះនៅជាខាងឆ្វេងដៃ ឆ្ងាយពន់ពេកក្រៃឥតគណនា សន្លឹមប្រិម ៗ ក្នុងជលសា បើកពីរទិវាផុតចេញទៅ » ។

*នៅទីនោះ លោក សើន ដៀប និទានខ្លីៗ ដែលគេធ្លាប់ឃើញក្នុងការរៀបរាប់អ្នកដំណើរចិន នាដើមសតវត្សទី ២០ លើក្មេងជនជាតិថៃនៅសិង្ហបូរី និងក្មេងនៅលង្កា ៖*

«ពួកក្មេងល័ង្កាហាក់ដូចខ្លីង　　ប្រិងអុំមថៃវទូកត្រសង
បោះប្រាក១ ស្លឹងក្នុងទិកលង　　មុច់យកជាម្ដងពុំរុញរា ។[៣៥] »

*(វគ្គ ៣៧) ។*

*បន្ទាប់មក កវីបានពណ៌នាពីកំពង់ផែ (កូឡំបូ) ដូចមានពាក្យពេចន៍តទៅនេះ ៖*

«ម្ខាងមានទំនុព្ពុទុពនិងថ្ម　　សាប់សូរឈ្លូឆគ្រុបវិលា
រលកទោកបាចសាចគុង្គា　　ផ្ទុប់នីងសិល្ល៉ាស្វូរក្លូងធា ។
ខាងមុក្ខសង្ខាងសិងនាវ្វិយ　　ចតត្រៀបដោ្យទីច្រេិនត្រៀបត្រា
ត្រើម្ខាងមេិលមានដេិមព្រិក្សា　　ត្រើម្ខាងមានផ្សាផ្ទះពេញពាស ។
មានពួកបារំាងខ្លឹងលន្ធា　　ដាក់ផ្សាលក់ដូច្រេិនដេជាស
រត្ថសែះរទែះភ្លេិងថ្កេិងសោភាស　　បេិកបរពេញពាសខ្លះឈប់ខាន ។
មេិលមានអរុក្ខជាតីដេិមស្រោងស្រេិង　　ត្រឈៃត្រឈេិងមែកយោនយាន
ព្រីក់ព្យាល័ជាជុះសពស្ពាន　　ខ្មោះដូងស្វាួ្យមៀនស្លាពុទ្រា ។[៣៦] »

*លុះឃើញពោធិព្រឹក្ស កវីមានចេតនានឹកដល់ព្រះសម្មាសម្ពុទ្ធ ៖*

«ពោទ្វីព្រិក្ស្សអាធិក់នៅស្លោមស្លិក់　　រំឭដកាលអង្គព្រះសាស្ដា

---

(៣៥)　ពួកក្មេងលង្កាហាក់ដូចក្លិង្គ　　ប្រឹងអុំថែវទូកត្រសង
បោះប្រាក់ ១ ស្លឹងក្នុងទឹកលង　　មុជយកជាម្ដងពុំរញ៉រា » ។

(៣៦)　ម្ខាងមានទំនប់ទប់នឹងថ្ម　　ស័ព្ទសូរឈ្លូឆរគ្រប់វេលា
រលកបោកបាចសាចគង្គា　　ផ្ទប់នឹងសិលាសូរក្លួងធា ។
ខាងមុខសង្ខាងសឹងនាវា　　ចតត្រៀបដោយទីច្រើនត្រៀបត្រា
ត្រើយម្ខាងមើលមានដើមព្រឹក្សា　　ត្រើយម្ខាងមានផ្សារផ្ទះពេញពាស ។
មានពួកបារាំង ក្លិង្គ លន្ធា　　ដាក់ផ្សារលក់ដូរច្រើនដេរដាស
រថសេះរទេះភ្លើងថ្កើងសោភា(ស)　　បើកបរពេញពាសខ្លះឈប់ខាន ។
មើលមានរុក្ខជាតិដើមស្រោងស្រឹង　　ត្រឈៃត្រឈឹងមែកយោនយាន
ព្រឹក្សាលតាជុះសព្វស្ថាន　　ខ្នុរដូងស្វាយមៀនស្លាពុទ្រា ។»

ចារ្យិវុង្សទ្រងមានព្រះមេតា សេកសាប្រោស្នសត្វសព់ផែន្តី
ដលព្រះបរំមវុង្សទ្រងនីពាន ព្រះចង្កមកែវបានលង្កាខ្មីយ
បន្ទុះទុកនៅក្នុងចែត្តី សព្វថ្ងៃមាននៅកោះលង្កា ។[៣៧] »

*បន្ទាប់មកទៀត កវីបានរំឭកថា នៅទីនេះ មានអន្តរាគមន៍ដ៏អាក្រក់សោកសៅពីពួកអឺរ៉ុប តាមលំដាប់ប្រវត្តិសាស្ត្រនៃកោះនេះ ៖*

« ល័ង្ការពីដើមមានមហាខ្សត្រ សៀ្បរាជសំម្បត៍ក្រុងភុញ្ញា
លន្ទាច្ញាព់យកពុំមេតា ស្វូនវង្សខ្សត្រាជាអង្វែង ។
ឬស្តេចល័ង្កាគ្រានោះនៃ លោព្តកាំមគុនក្រៃពុំគិតឈ្វេង
សេចក្តីឈប់ស្លែះមិនសម្តែង យេិងចែងតែស្វូនឆ្នាំមយូ្វលុង ។[៣៨] »

(*វគ្គ ៣៩-៤៦ អក្ខរាវិរុទ្ធដើមឯកសារ*) ។

*នាវាចាកចេញពីកោះលង្កាជាបន្ទាន់ បើកលឿនបន្តដំណើរចំនួន ៩ ថ្ងៃ ៩ យប់ បានដល់កោះសូកូត្រា (វគ្គ ៤៧) ឃើញមានវាលភ្នំក្រំថ្មព្រៃព្រឹក្សា ហើយកវីរៀបរាប់ដោយលន្ទង់លន្ទោចថា ៖*

« ភេត្រាចេញច៍របរបេិកស្មោះ ពីកោះល័ង្កាពុំបង្អង
ប្រាំមថ្ងៃប្រាមយុប់កាត់ជំម្រង ដលចុងកោះ ១ ហៅសុកុត្តរ៉ា ។
កោះនោះមានភ្នំធំទូល្យ ជជាយកន្តាលដែនជុលសា
មានដីមានភ្នំឥតព្រិក្សា ឥតការអាសារជាស្វូនសោះ ។
មេិលកោះស្រណោះ កេិតលង្វែកមេិលមេឃិមេឃិឆ្ងាយខ្សាយពុងពោះ
ព៌ពកព្រះញបកជ្ផាយស្មោះ សន្និយាព្រាតប្រុះសិងដ៏វា ។[៣៩] »

---

(៣៧) « ពោទ្ធីព្រឹក្សអធិកនៅស្លោមស្លឹក រំឭកកាលអង្គព្រះសាស្តា–
ចារ្យវង្សទ្រង់មានព្រះមេត្តា សិក្សាប្រោសសត្វសព្វផែនដី ។
ដល់ព្រះបរមវង្សទ្រង់និព្វាន ព្រះចង្កូមកែវបានលង្កាខ្មី
បញ្ចុះទុកនៅក្នុងចេតិយ សព្វថ្ងៃមាននៅកោះលង្កា ។ »

(៣៨) « លង្កាពីដើមមានមហាក្សត្រ សោយរាជសម្បត្តិក្រុងភពភារ
លន្ទាចាប់យកពុំមេត្តា សូន្យវង្សក្សត្រាជាអង្វែង ។
ឬស្តេចលង្កាគ្រានោះនៃ លោភកាមគុណក្រៃពុំគិតឈ្វេង
សេចក្តីឈប់ស្លេះមិនសម្តែង យើងចែងតែសូន្យឆ្នាំយូរលង់ ។ »

(៣៩) « ភេត្រាចេញចរបរបើកស្មោះ ពីកោះលង្កាពុំបង្អង់

*ចាប់ពីកោះនេះទៅ កប៉ាល់បើកបន្តអស់ ២ ថ្ងៃ បានដល់សូម៉ាលី* (*វគ្គ ៥១*) *ហើយបើកសសៀរតាមឆ្នេរសមុទ្រ រហូតដល់ស្រុកអាដែន, នៅទីនោះ មានភ្នំនិងដីបែកក្រហែង ឥតមានដំណាំដាំដុះសោះឡើយ គឺជាស្រុកក្ដៅរីងស្ងួត គ្មានភ្លៀងក្រោមកំដៅព្រះអាទិត្យយ៉ាងខ្លាំង* (*វគ្គ ៥៣*) *។ ដូចជានៅស្រុកឯទៀតដែរ, កេត្រាឈប់សម្រាក ហើយកវី សើន ដៀប ពណ៌នាពីប្រជារាស្ត្រនិងទំនៀមទម្លាប់ស្រុក បង្ហាញថា ៖*

«មានភ្នំមានដីឥតព្រៃព្រិក្ស ថ្ងៃក្ដៅពុន្លិក់ឥតភ្លៀងណា
ពីន្នាំភ្លៀងម្ដងពុំមុសា ជាស្រុកវេទនាក្នុងលោកីយ្យ ។
ទីនោះជាដែនស្រុកអារ៉ាប់ នៅផ្ទាប់ជិតទៀពផ្លូវសូរ៉ី
ទិន្នច៍ត្រេច់ជាប្រក្រដី ហៅកោណ្ណវីធ្វីជាកុំណត្ន ។[៤០]»

(*វគ្គ ៥៣-៥៤*) *អក្ខរាវិរុទ្ធដើម ។*

*បន្ទាប់មក កប៉ាល់បើកបរកាត់តាមសមុទ្រក្រហម អស់រយៈពេល ៤ ថ្ងៃ ហើយបន្តកាត់តាមព្រែកជីកស៊ុយអេស* (Suez) *ចំនួនពេល ១ ថ្ងៃ* (*វគ្គ ៥៥-៥៦*) *ហើយកវីបង្ហាញថា ៖*

«សង្ខាងព្រែកជីកក្រឡេកឈ្មៀង ល្វើព្រល្វេងធំទែងឆ្ងាយលន្ហុង
លុន្លោចស្រង្វោចខ្លោចក្នុងអង្គ វាលវែងសន្លុងផុតនេត្រា ។
ល្ហល្ហាចសិងខ្យាចថ្ងៃក្ដៅដី លំម្ដាជឥតព្រៃស្មៅបន្លារ
ឆ្ងាយល្វិងពុំដិងជាទ្បីណា រាក្សឹយស្វរ្យាក្ដៅកន្លង ។[៤១]»

ប្រាំថ្ងៃប្រាំយប់កាត់តម្រង់ ដល់ចុងកោះ ១ ហៅសូកូត្រា ។
កោះនោះមានភ្នំធំទូលាយ ជជាយកណ្ដាលដែនជលសា
មានដីមានភ្នំឥតព្រឹក្សា ឥតការអសារជាសូន្យសោះ ។
មើលកោះស្រណោះកើតសង្វេគ មើលមេឃ ៗ ឆ្ងាយខ្វាយពុងពោះ
ពពកព្រះពាយបកជាយស្មោះ សន្ធិយាព្រាតប្រុះសឹងតារា ។»

(៤០) « មានភ្នំមានដីឥតព្រៃព្រឹក្ស ថ្ងៃក្ដៅពន្លឹកឥតភ្លៀងណា
ពីរឆ្នាំ ភ្លៀងម្ដងពុំមុសា ជាស្រុកវេទនាក្នុងលោកិយ ។
ទីនោះជាដែនស្រុកអារ៉ាប់ នៅផ្ទាប់ជិតទៀបផ្លូវសូរិយ
ទិនករចរត្រេចជាប្រក្រដី ហៅគោវិថីជាកំណត់ ។»

(៤១) « សង្ខាងព្រែកជីកក្រឡេកឆ្មៀង ល្វើយល្វេងធំទែងឆ្ងាយលន្លង់

*(វគ្គ ៥៨-៥៩) អក្ខរាវិរុទ្ធដើម ។*

*កប៉ាល់ចេញពីព្រែកជីកស៊ុយអេស បើកដល់កំពង់ផែព័រសាអ៊ីត* (Port-Saïd) *ក្នុងដែនម៉ាសើយ* (Massaoua), *កវីនិពន្ធមានការចាប់អារម្មណ៍លើស្ថាបត្យកម្មទីក្រុងនេះ ៖*

«ផ្ទះថ្មច្រើនថ្នាក់ហាក់យុលស្អាត រៀបរ្យសង្ឃាតជៀ្យជំណែង
ទំនីញជាកលុកមានជៀ្យល្វែង តែងតាមបែព យ៉ាងដែន្តីថ្មី ។(៤២)»

*(វគ្គ ៦៣) ។*

*បន្តមកទៀត នាវាបើកបរឆ្ពោះទៅដែនទឹកសមុទ្រអ៊ីតាលី ឆ្លងដល់កោះស៊ីស៊ីល* (Sicile) *ឃើញភ្នំខ្ពស់ធំ, ផ្ទះថ្មស្អាត និងដើមរុក្ខជាតិដុះខ្ពស់ស្រោងស្រឹង គន់ទៅគួរឲ្យស្រណោះ ។ ដំណើរអស់រយៈពេលពីរថ្ងៃក្រោយមក ដល់កោះគស់* (Corse) *ដែលមានទេសភាពដូចគ្នានឹងកោះស៊ីស៊ីលដែរ ។*

## ការមកដល់ក្រុងម៉ារសីយ

*កវី សើន ជៀប ពុំបានពណ៌នាពីប្រទេសនៅអឺរ៉ុបនានា ដែលលោកបានជួបប្រទះជាដំបូងទេ, នេះប្រហែលជាដំណើរឆ្លងកាត់សមុទ្រខ្ញីពេក ហើយលោកចាប់រៀបរាប់បង្ហាញពីក្រុងម៉ារសីយ ដែលជាជំនួបដំបូងនឹងប្រទេសបារាំង (វគ្គ ៦៧) ។ កវីនិពន្ធគូសបង្ហាញអ្នកអាន ដូចជាផ្ទាំងគំនូរមួយ ៖*

«កំពងភេត្រាចតដងរៀប របៀបរៀបរ្យជៀ្យជំណែង
ដំណ័ត៍ត្នាតាមកន្លែង ទំនិញទិញតែងគ្រុបវេលា ។
ដងក្តោងស្រោងស្រិងត្រដឹងស្រួដ ខ្សែយិតយោងតូចគ្រុប់ភេត្រា
ដូចកាលមន្ទលដេមព្រឹក្សា ខ្សែដូចល័ជាពាន់ពាក់នៅ ។
មានភ្នំត្រសុំដេមព្រឹក្សា ថ្មជាគ្រឹះហ៊ាសង់លើនៅ

លន្លោចស្រងោចខ្លោចក្នុងអង្គ វាលវែងសន្លុងផុតនេត្រា ។
ល្ហល្ហោចសឹងខ្សាច់ថ្ងៃក្តៅដី លម្អាច (?) ឥតព្រៃស្មៅបន្លា
ឆ្ងាយល្វឹងពុំដឹងជាទីណា ស្មើសុរិយាក្តៅកន្លង ។»

(៤២) « ផ្ទះថ្មច្រើនថ្នាក់ហាក់យល់ស្អាត រៀបរយសង្ឃាតដោយដំណែង
ទំនិញដាក់លក់មានដោយល្វែង តែងតាមបែបយ៉ាងដែនដីថ្មី ។ »

ភីមានស្ពានស្អិតពីចិតឆ្លៅ          ១ ហៅកុំផែងវង្គឡុងគង ។[៤៣] »

(*វគ្គ ៦៨-៧១*) *អក្ខរាវិរុទ្ធឯកសារដើម ។*

*នៅបរិវេណជុំវិញ លាតសន្ធឹងដោយសួនឧទ្យាន មានបុប្ផាដុះក្រអូបឈ្ងុយឈ្ងប់ ។ នៅលើកំពូលភ្នំ មានវិហារធំខ្ពស់ស្កឹមស្កៃសម្រាប់អម្រុង «អង្គម៉ារីមាតាព្រះយេស៊ូ» [បារាំងហៅថា* Notre-Dame de la Garde] (*វគ្គ ៧៣*) *ហើយដើម្បីទៅមើលវិហារនេះ គឺត្រូវឡើងតាមជណ្ដើរយន្ត ឬក៏ឡើងដោយតាមផ្លូវដើរវាងនឿយលំបាកប្រាណ ។ នៅក្រុងម៉ារសីយ មានមហាវិថីសំខាន់មួយឈ្មោះ «កានវិយា»* (La Canebière) *ដែលល្បីឈ្មោះសព្វស្ថានឯក្រៅប្រទេស ។ វិថីនេះ មានមនុស្សកុះករ ល្បីល្បាញដោយមានផ្ទះល្អភ្លឺចិញ្ចាចហៅ «ផ្ទះខ្លូវ»* (maisons dorées) *គឺជាផ្ទះស្រីឆើតឆាយ ព្រមទាំងមានអាហារកេសជ្ជៈនិងមហោស្រពផង ។ តាមដងវុក្ខវិថី មានផ្ទះថ្មល្អនៅជាជួរ ហើយមានរទេះសេះនិងរថអគ្គិសនី (រថទឹកក្រុត* tramways) *រត់ពាសពេញ ។ តាមមាត់ខ្លះៗ គេឃើញមានម៉ាស៊ីនបញ្ចេញទំរាងជាសត្វសេះ, ពានរ, ខ្លាឃ្មុំ ឈរជាប្រក្រតី ដែលមានបែងអក្ខរាតម្លៃទំនិមួយៗ គឺបោះលុយក្នុងផ្ទៃទំនៅក្នុងដែលចង់បាននោះចេញមកក្រៅ ។ នៅទីខ្លះ ឃើញគុហាល្អាងថ្ម មានទឹកស្អាតក្ដៅត្រជាក់ដែល សាធារណជនអាចផ្ញូតបាន ហើយទីខ្លះទៀត មានកន្ទែងកាត់សក់និងកន្ទែងបោកអ៊ុតសំលៀកបំពាក់ (វគ្គ ៧៤-៨២) ។*

*កវីនិពន្ធស្ទេះពិពណ៌នាពីខេត្តម៉ារសីយ ហើយផ្ដើមនិទានពីប៉ារីស ៖*

«យើងនឹងនីទានត៍ទៅខ្មី          បារីសក្រុងក្រៃចមពិភព្ព

---

(៤៣) កំណៃ ៖ « កំពង់ភេត្រាចតតម្រៀប          របៀបរៀបរយដោយតំណែង
តំណតគ្នាតាមកន្លែង          ទំនិញទិញតែងគ្រប់វេលា ។
ដងក្ដោងស្រោងស្រឹងត្រដឹងស្រួច          ខ្សែយឹតយោងតូចគ្រប់ភេត្រា
ដូចកាលមណ្ឌលដើមព្រឹក្សា          ខ្សែដូចលតាព័ន្ធពាក់នៅ ។
មានភ្នំត្រសុំដើមព្រឹក្សា          ថ្មជាគ្រឹះហាសង់លើនៅ
ភិមានស្ថានស្ថិតពិចិត្រឆ្លៅ          ១ ហៅកំផែងវាំងឡុងគង ។ »

វាំងនេះ បារាំងហៅ វាំងបូរេលី (Palais Borély) ។

ជាដេិមស្រុកធំសំជាម្លុប          ល្បិយព្ទសុះសព ក្នុងភុញ្ញា ។
បារីស៍ជាក្រុងស្រុកបារាំង្សែស          ខ្ពស់លេិសប្រទេស្នក្នុងភសធ្ធា
ល្បីសពភូមភុព្កផែនភារា          ឥតន៍គរណានឹងស្មេិបាន ។
ទ្បេិងរត្នភ្លេិងចេញពីម៉ារសី          បេិកឆ្ពោះស្មោះវៃច៍ទៅថ្កាន
១ យុបភ្លឺទ្បេិងមេិលយលស្ថាន          មោងប្រាំម្បួនក៏បានដល់ក្រុងក្រៃ ។[៤៤]»
*(អក្ខរាវិរុទ្ធដើម)* ។

*សេីន ដៀប ពុំសូវយកចិត្តទុកដាក់នឹងយានជំនិះ ដែលបានធ្វើដំណើរចេញពីស្រុកខ្មែរប៉ុន្មានទេ, តែផ្ទុយទៅវិញ លោកចាប់អារម្មណ៍និងរញ្ជួយចិត្តលើទេសភាពនានា ដែលលោកបានឆ្លងកាត់ នាំឲ្យលោកមានអារម្មណ៍ស្រណោះស្រុកដើម (វគ្គ ៨៣-៩១) ។ ពេលមកដល់ក្រុងប៉ារីស កវីនិពន្ធហាក់ដូចជាវិវត្តន៍ដោយស្រួលក្នុងពិភពថ្មី ឥតនឹកឃើញនិយាយពីអ្នកដែលបានធ្វើដំណើរជាមួយ ឬនិទានពីអ្នកដែលជូននាំមក, លោកគ្រាន់តែមានវាចាថា ៖*

« លុះដលបារីសទីសំរេច          ច្វាករត្នភ្លេិងត្រេចច៍ជុំពោះ
ទ្បេិងរត្នសៃះផ្ទុកអ្សរ៍បេស          ច៍ឆ្ពោះដំរងត្រងប៉ាសុី ។
ទ្បេិងទៅនៅផ្ទះពុំមានព្រួយ          ដែលរាជ្ការជ្ឍួយជួលទុកខ្មី
សំរ៉ាបអំម្រុងអង្គមុន្ត្រី          ប្រទេស្នដលថ្មីនៅផ្ទះនោះ ។[៤៥]»

---

(៤៤) « យើងនឹងនិទានតទៅខ្មី          ប៉ារីសក្រុងក្រៃចមពិភព
ជាដើមស្រុកធំសមជាម្លប់          ល្បីឮសុះសព្វក្នុងភពា ។
ប៉ារីសជាក្រុងស្រុកបារាំងសេស          ខ្ពស់លើសប្រទេសក្នុងពសុធា
ល្បីសព្វភូមិភពផែនភារា          ឥតនគរណានឹងស្មើបាន ។
ឡើងរថភ្លើងចេញពីម៉ារសើយ          បើកឆ្ពោះស្មោះរៃចរទៅថ្កាន
១ យប់ភ្លឺឡើងមើលយល់ស្ថាន          ម៉ោងប្រាំបួនក៏បានដល់ក្រុងក្រៃ ។ »
(អត្ថបទកែតាមអក្ខរាវិរុទ្ធទំនើប) ។

(៤៥) « លុះដល់ប៉ារីសទីសម្រេច          ចាករថភ្លើងត្រេចចរចំពោះ
ឡើងរថសេះផ្ទុកអស់របស់          ចរឆ្ពោះតម្រង់ត្រង់ប៉ាសុី ។
ឡើងទៅនៅផ្ទះពុំមានព្រួយ          ដែលរាជការជួយជួលទុកខ្មី
សម្រាប់អម្រុងអង្គមន្ត្រី          ប្រទេសដល់ថ្មីនៅផ្ទះនោះ ។ »
(កែតាមអក្ខរាវិរុទ្ធទំនើប) ។

*(វគ្គ ៩២-៩៣, រក្សាអក្ខរាវិរុទ្ធដើម)* ។

*សើន ដៀប សំណាក់នៅនិវេសនស្ថាន ដែលរដ្ឋបាលបារាំងទុកបម្រុងជូនឲ្យមន្ត្រីបរទេសមកដល់ថ្មី ស្នាក់នៅ ហៅ «វិឡាដេសាឡេ»* (Villa Désalé) *ព័ទ្ធជុំវិញដោយផ្ទះ ដែលសង់ឡើងពីថ្មភ្នំជាច្រើនជាន់ ។ ភូមិគ្រឹះឋិតនៅវិថីឈ្មោះ ដុកទ័រប្លាង្ស* (Docteur Blanche) *ក្នុងសង្កាត់ទី ១៦ ជាកន្លែងដែលអភិជននិងអ្នកមានស្តុកស្តម្ភរស់នៅ* (*វគ្គ ៩៤*) ។

## គំហើញក្រុងប៉ារីស — ពិពណ៌ពិភពលោក

*សើន ដៀប ចាប់ផ្តើមទៅជួបក្នុងការគួរសមជាមួយអាជ្ញាធរ ដែលគ្រប់គ្រងលោក មុននឹងទៅទស្សនាសោភណភាពពិព័រណ៍ ៖*

«លុះបានសំម្រានខ្យានកាយ្យា ១ ទន់ទេវាឥតហ្មងសៅ
នាំគ្នាម្នីម្នាលីលាទៅ ថ្កានស្ពានលំនៅកំមីសារ៉្យា ។
មុនសៀអើនីកូឡា [៤៦] ចិន្តាស្មោះ ទ័ទួលជុំពោះសួរកិចការ
រាក់ទាក់ស្រាកស្រួលចូលចីន្តា ស្រេច់ហៀនាំលាលីទៅខ្មី ។
ចូលទៅគុំនាពអគ្គសៃណា មានចិតមេតាសពសេចក្តី
ពុំមានសៅហ្មងឆ្គងការអ្វី ស្រដីសាកសួរគ្រុបកិចការ ។
មុនសៀអើដីក្រេ [៤៧] អគសៃនី មានចិតបេត្តីឥតអប្បមា
សាទ័ត្រេកអរសោមសន្យា ស្រេចហៀលាកលាចេញថ្វាកវ៉ៃ ។
ដលស្ពានសំម្រានកុំសានអង្គ បីថ្ងៃពុំលុងលីលាខ្មី
ដើមើលតាំតុះជាប្រក្រតី តាមក្តីបំណងប៉ងប្រថ្នា ។

(៤៦) Monsieur Nicolas, alors commissaire de l’Exposition pour l’Indochine (cf. Pierre Lamant, *L’affaire Yukanthor (juillet–décembre 1900)*, Thèse, Paris, Université Paris III, 1979, p. 130–1) ។ ស្នងការ (កម្មីសៀរ) ពិព័រណ្ឌ៍ណ៍ឥណ្ឌូចិន បានសរសេរសៀវភៅមគ្គុទេសក៍មួយ សម្រាប់ពិព័រណ៍នេះ ។ សូមអាន Pierre Nicolas, *Notices sur l’Indo-Chine, Cochinchine, Cambodge, Annam, Tonkin, Laos, Koang-Tchéou-Ouan, publiées à l’occasion de l’Exposition Universelle de 1900*, Paris, 1900 ។

(៤៧) Monsieur Decrais (cf. Lamant, 1979, p. 132) ។

តាំតុះរោងទងសងស្អាងស្អាត		តែងជាប្រសាធគ្រុបភារា
ដុំម្នាងជាងឆ្លាកកន្លោរេចណា		តាមបែពប្រាជ្ញាគ្រុបប្រទេស្ន ។
នឹងមើលគ្យគនដំម្បនសព		ពុំមានស្កលស្កបទីនីវែស្ន
គ្រុបស្ថានភីមានសិងវីសែស្ន		ប្រទេស្នជួបជុំកុំកុះក ។
មនុសម្នាជាម៉ើនសលសែនកោដ្ឋ	ខ្លះដេិខ្លះលោតខ្លះឈបឈ៍
សាបស្វរស្វេរដូរជន្ត្រីខ្នារខ្មរ		ស្វរសាចកន្ទឹងត្របហឹងស៉ាន ។
ត្រូកាដេរ៉ូទូរអេផេល [៤៨]		គនមើលប្រហែលស្ថានភីមាន
ទូរឌុម៉ូត [៤៩] នឹងប្រែឲ្យអសអាន	នីទានមានក្នុងក្រុងភារា ។ [៥០] »
(*វគ្គ ៩៤-១០៤, អក្ខរាវិរុទ្ធដើម*) ។

---

(៤៨) Trocadéro, Tour Eiffel ។

(៤៩) Tour Dumotte ។

(៥០) កំណែតាមអក្ខរាវិរុទ្ធទំនើប ៖

« លុះបានសម្រាន្តក្សាន្តកាយា		១ ទន់ទេវាឥតហ្មងសៅ
នាំគ្នាម្ទីម្នាលីលាទៅ		ថ្កានស្ថានលំនៅកំមីសារីយ៉ា ។
ម៉ុនសៀអើនីកូឡាចិន្តាស្មោះ		ទទួលចំពោះសួរកិច្ចការ
រាក់ទាក់ស្រោកស្រួលចូលចិន្តា		ស្រេចហើយនាំលាលីទៅខ្មី ។
ចូលទៅគំនាប់អគ្គសេនា		មានចិត្តមេត្តាសព្វសេចក្តី
ពុំមានសៅហ្មងឆ្គងការអ្វី		ស្រដីសាកសួរគ្រប់កិច្ចការ ។
ម៉ុនសៀអើជីក្រេអគ្គសេនី		មានចិត្តបេតីឥតឧបមា
សាទរត្រេកអរសោមនស្សា		ស្រេចហើយលាកលាចេញចាកវ៉ៃ ។
ដល់ស្ថានសម្រាន្តកម្សាន្តអង្គ		បីថ្ងៃពុំលង់លីលាខ្មី
ដើរមើលតាំងតុជាប្រក្រតី		តាមក្តីបំណងប៉ងប្រាថ្នា ។
តាំងតុរោងទងសង់ស្អាងស្អាត		តែងជាប្រាសាទគ្រប់ភារា
តំណាងជាងឆ្លាក់ឆ្លៅរចនា		តាមបែបប្រាជ្ញាគ្រប់ប្រទេស ។
នឹងមើលគយគន់តំបន់សព្វ		ពុំមានស្កល់ស្កប់ទីនិវេសន៍
គ្រប់ស្ថានភិមានសឹងវិសេស		ប្រទេសជួបជុំកុំកុះករ ។
មនុស្សម្នាជាម៉ឺនសល់សែនកោដិ		ខ្លះដើរខ្លះលោតខ្លះឈប់ឈរ
ស័ព្ទស្វរត្រូវត្រន្រ្ទីខ្នារខ្មរ		ស្វរស័ព្ទកណ្តឹងទ្រហឹងស៊ាន ។
ត្រូកាដេរ៉ូទូរអេផេល		គន់មើលប្រហែលស្ថានភិមាន
ទូរឌុម៉ូតនឹងប្រែឲ្យអស់អាន		និទានមានក្នុងក្រុងភារា ។ »

លោក សើន ដៀប ចេញទៅកន្លែងមួយទៀត ដើម្បីទស្សនា ហាក់ពុំមានការរំភើបពិសេសនូវការសាងសង់ប្រាសាទអង្គរវត្តឡើងវិញ ។ លោកឃើញ «ក្បាច់រចនារូបនាគ, គ្រុឌ, យក្ស, វេស្សវ័ណ, ព្រះពាយ, ព្រះភ្លើង (អគ្គី), ព្រះទសរថ[៥១], ព្រះអាទិត្យប្រយុទ្ធដណ្ដើមជ័យ» (វគ្គ ១០៥) ។ លោកសង្កេតឃើញមាន «ទេវៈ, យក្ស, ខ្លា, ទាហាន ហើយទាំងអស់នេះល្អប្រណីត គួរឲ្យគយគន់មាននៅគ្រប់ល្វែង» (វគ្គ ១០៦) ។ លោកចូលក្នុងវិមានតាំងតុ ប្រទេសម៉ាដាកាស្ការ (Madagascar) ទស្សនាដោយពិនិត្យពិច័យតែឥតមានធ្វើការអធិប្បាយ ពីគំនូរនិទានបង្ហាញកាលគ្រាសង្គ្រាមម្ចាស់ក្សត្រីរ៉ាណាវ៉ាឡូ, ពីការចាញ់សង្គ្រាមនេះ ហើយការទទួលគ្រប់គ្រងរដ្ឋបាលដោយបារាំងសេស[៥២] ។

មកដល់ទួរអេផេល (Tour Eiffel) កវីនិពន្ធមានការចាប់អារម្មណ៍យ៉ាងខ្លាំងដោយពណ៌នាយ៉ាងលំអិត ៖ «ទួរអេផេលនេះមានកម្ពស់ ៦០០ ហត្ថ, មានច្រើនជាន់ថ្នាក់ខ្ពស់ត្រដឹមត្រដួច ។ នៅពេលយប់ លើកំពូលស្រួច មានពន្លឺអគ្គិសនីភ្លឺដូចវិមានមាស (វគ្គ ១១៥) ។ មានគ្រឿងយន្តឡើងចុះឥតឈប់ឈរ ដើម្បីជួយនាំអ្នកកំសាន្តទៅមក ដោយស្រួលជំនួយកម្លាំងពុំមានព្រួយ ។ កវីដើរខាងក្រោម ដើម្បីស្ដាប់សូរសំឡេងគងវង់តូចធំ, នៅសង្ខាងមាគ៌ា មានសួនច្បារប្រកបដោយបុប្ផាកូលាបពាសពេញ, មានស្រះស្រង់ទឹកជ្រោះថ្លាឆ្វង់ល្អសោភាក្រអូបសាយ ផ្ដល់ភាពស្រទន់ត្រជាក់ ធ្វើឲ្យអ្នកដំណើរសប្បាយក្នុងចិត្ត» (វគ្គ ១១៦-១១៧) ។

កវីនិពន្ធទៅទស្សនាទួរឌុម៉ូត (Tour Dumotte) ជាទីកន្លែង ដែលមានវិមានតាំងតុលើប្រទេសនៅជិតចក្រវាឡ មាន «តែងជាព្រៃ, វាល, នគរ, ស្រុកដោយខណ្ឌចំណែកឡែកដោយមុខ ។ មនុស្សកុះករមកមើលកំសាន្តសប្បាយ “វិមានចក្រវាឡ” ដែលមានស្រុកនានាក្រោមអាណាព្យាបាលបារាំង, ជ្វា,

(៥១) បិតាព្រះរាម ក្នុងរឿងរាមកេរ្តិ៍ ។

(៥២) កវីនិពន្ធប្រើពាក្យ ជ្វា ដើម្បីសម្គាល់ជនជាតិប្រទេសម៉ាដាកាស្ការ ។

*ចិន និងជប៉ុន ។ ល្វែងដែលមានតាំងតុស្រុកលង្កា ឃើញមានចេតិយព្រះជិនស្រី ហើយល្វែងសម្រាប់ស្រុកជប៉ុន មានផ្ទូរអធិរាជ» (វគ្គ ១២១) ។*

*បន្ទាប់មក កវីនិពន្ធបានចូលទៅទស្សនាវាំងតូច* (Petit Palais) *និងវាំងធំ* (Grand Palais) *ដែលមានតុបតែងល្អប្រណីត ហើយលោកក៏បានពោលថា «ធ្លាក់ធ្លៅប្រៀបទៅដូចកាលស្ថានទេវតា» (វគ្គ ១២២) ។ ចេញមកក្រៅលោកឃើញ «ស្ពានធំឧត្តុង្គឧត្តម ហៅស្ពានអាឡេក្សង់ត្រា ស្តេចរុស្ស៊ី»*(៥៣)*, បន្ទាប់មកទៀត ឃើញវាំងភ្នំពេញ មានរោងរាំរបាំល្អសោភី ។ នៅទល់មុខនោះ មានភោជនីយដ្ឋាន «កាផែ»* (Café) *ដែលគេអាចស្រស់ស្រូបអាហារ, ភេសជ្ជៈ ដូចជាកាផែ, តែ ឬសុរាផ្សេងៗ ទាក់ទាញភ្ញៀវមកបរិភោគរៀងរាល់ថ្ងៃ ។ នៅម្ខាងទៀត មានផ្ទះលាវនិងវិហារយួនឧត្តមសមសួន មានតាំងប្រដាប់ប្រដា ដោយមានទស្សនិកជនចេញចូលមើលឥតឈប់ (វគ្គ ១២៤) ហើយឃើញ «មានស្ពានយន្ត នាំអ្នកទស្សនាទៅមកមិនហត់នឿយ» (វគ្គ ១២៥) ។ លោក សើន ដៀប ចាប់អារម្មណ៍ទៅលើអក្វារិយ៉ុំ* (Aquarium) *បង្ហាញពីក្នុងសមុទ្រ មានត្រីគ្រប់បែបយ៉ាងហែលនៅលើក្តារសំពៅលិចនៅបាតជលសាគរ ហើយលោកបានពោលវាចាបន្ថែមថា ៖*

«មានផ្ទះសងប្រាសលើជាក្រោម មនុស្សផោងចោមរោមព្រោះយល់ផ្លែក
ដើចូលមូលមីជាអាណែក ចំឡែកចងមើលអសកិចការ ។
មានស្រីបិតមុក្ខនឹងកន្សែង ត្រច់ងអង្គតែងវុង្គភក្ត្រថ្លារ
ឈ៍នៅមុក្ខឆាកប្រាពអប្សរារ៍ សួរសាការអ្វីស្ដីយប្រាពភ្លាម ។
ប្រាពស្មោះជុំពោះ ១ រំពេជ សេចគ្រេចកិចការពុំទីមទាម
ទាំឈ្មោះរបែសស្មោះទាំនាម្ក ទាំយាមនាលិកាមោងវេលា ។
របែសតាំគុះគ្រុបប្រទេស្ន សិងល្អវិសែស្នឥតគុន្នា
ក្របេនឹងចែងថ្លែងឡេយណា អប្បម៉ាពុំបានគ្មានខ្វាះអ្វី ។(៥៤)»

---

(៥៣) Alexandre III ជាអធិរាជប្រទេសរុស្ស៊ី ។

(៥៤) កែ ៖ « មានផ្ទះសង់ប្រាសលើជាក្រោម មនុស្សផងចោមរោមព្រោះយល់ប្លែក
ដើរចូលមូលមីរជាអនេក ចម្លែកចង់មើលអស់កិច្ចការ ។
មានស្រីបិទមុខនឹងកន្សែង ត្រចង់អង្គតែងវង់ភក្ត្រថ្លា

*(វគ្គ ១២៨-១៣៣, រក្សាអក្ខរាវិរុទ្ធដើម)* ។

### **វិថីឆងសេលីសេ** (L’Avenue des Champs-Élysées)

*លោក សើន ដៀប ចាប់ចិត្តចាប់ភ្នែកយ៉ាងខ្លាំងនឹងភាពអស្ចារ្យនៃទីកន្លែង សង់ អេលីស្ស៊េ ឃើញមានវិមាននានាសម្រាប់រដ្ឋបាល, ទីធ្លា, វិថីធំៗ អប ដោយដើមឈើត្រង់ៗ ជាជួរ, រទេះសេះ និង «រទេះយន្តលឿនឯងពុំបាច់ ភ្លើង»* (tramways) *ដឹកនាំមនុស្សទៅមកឥតឈប់ឈរ ហើយកវីនិពន្ធបានឲ្យ យោបល់ថា ៖ «នេះជាសក្ខីភាពនៃកម្រិតវិទ្យាសាស្ត្រនិងភាពថ្កើងរុងរឿងក្នុង បូរី» ។ កវីបានបន្តការពណ៌នាទៅទៀត ពីមនុស្សកុះករផង ត្រសងទាំង ប្រុសស្រីឃ្មាតខ្មីដើរដោយដងមាគ៌ា ។ លោក សើន ដៀប* «គន់ភ័ក្ត្រអស់ស្រីស កំផ្លង់ ត្រចង់ត្រចះជ្រះអង្គា រូបឆោមលោមពណ៌សមសោភា វង់ភក្ត្រជ្រះថ្លាស្រស់ ប៉ប្រែ មុខឈ្មេងដងខ្លួនដូចកិន្នរី ស្រមៃរព្ទកនឹកមិនភ្លេច» *(វគ្គ ១៣៧-១៣៩) ។ មកដល់កាស៊ីណូដឺប៉ារីស* (Casino de Paris) *ដែលមានសំដែង មហោស្រពរៀងរាល់យប់ដូចជារបាំ, ចម្រៀង, ក្បាច់សួព្រ័ត្រលោតហក់ដាំ ដូង ជាដើម សម្រាប់សាធារណជន» ។ លោកកវីទស្សនាកាស៊ីណូ ដែលនៅ ខាងក្នុង មានបម្រើស្រា, តែ, កាហ្វេ ហើយមាន* «ស្រីសល្អដូចកិន្នរី មុខមាត់ ប្រិមប្រិយថ្ពាល់បំព្រ ដោះក្បុំសមទ្រូងអង្គឥតហ្មង ត្រេចដើរត្រសងសព្វសន្ធិយា ។ បើមានចិត្តស្និទ្ធគិតប្រតិព័ទ្ធ ហាមាត់មធុរពោះស្មោះចិន្តា អញ្ជើញផឹកតែកាហ្វេស្រា ស្រេចនាំលីលាត្រឹហាស្ថាន ។ ស្ម័គ្រចិត្តស្នាលស្និទ្ធរួមនោរម្យ សុខដុមជាសុខ និរទុក្ខក្សាន្ត កាស៊ីណូដឺប៉ារីសទីកំសាន្ត កើតទុក្ខប៉ុន្មានរលាយបង់» *(វគ្គ ១៤០-១៤៦)* ។

---

ឈរនៅមុខឆាកប្រាប់អស់អាថ៌ ស្សួរសោកការអ្វីស្តីប្រាប់ភ្លាម ។
ប្រាប់ស្មោះចំពោះ ១ រំពេច សេចគ្រេចកិច្ចការពុំទីមទាម
ទាំងឈ្មោះរបស់ស្មោះទាំងនាម ទាំងយាមនាឡិកាម៉ោងវេលា ។
របស់តាំងតុគ្រប់ប្រទេស សឹងល្អវិសេសឥតគណនា
ក្របើនឹងថែងថ្លែងឡើយណា ឧបមាពុំបានគ្មានខ្វះអ្វី ។»

## ទីកន្លែងមហោស្រពនិងកំសាន្ត

*កវីបានរៀបរាប់បន្តថា នៅទីក្រុងប៉ារីស មានប្រហែលហុកសិបថ្វាយទីមហោស្រពនិងកន្លែងកំសាន្តនានា ដូចជា ឱប្បេរ៉ា* (Opéra), *រោងល្ខោនសាត្តឡេ* (théâtre du Châtelet), *វង់កុំមេឌី* (Comédie) *។ល។ ជាសំណង់ល្អអស្ចារ្យ ៖* «រោងរាំឱប្បេរ៉ាប្រសើរ ជណ្ដើរក្បាច់សឹងថ្មកែវស្រស់ ជម្នាងឆ្លាក់ឆ្លៅពុំមានខ្ចោះ កំពស់ច្រើនថ្នាក់ហាក់ស្រីសួគ៌ ។ ប្រទីបង្វាលាជាសលពាន់ ជាន់លើជាន់ក្រោមក្រាលកាំម្ទី ក្រុមទីសព្វល្វែងតែងពីសី កៅអីសឹងទិព្វទែនសុវណ្ណា ។ ពួករាំសមទ្រង់អង្គស្រៀបស្រល់ គន់ពុំមានខ្ចោះតួ ១ ណា សោតសឹងនារីភ័ក្ត្រជ្រះថ្លា ហាក់ទេពធីតាចុះចាកស្ថាន» (*វគ្គ ១៥០*) *។*

*នៅរោងល្ខោន* «សាត្តឡេ (Châtelet) ទីនោះសឹងផ្ចិតផ្ចង់ ខ្ពង់ខ្ពស់ត្រដុងទាំងភីមាន ចៀមចំព្រៃព្រំក្រាលគ្រប់ស្ថាន សព្វល្វែងសឹងមានពុំខ្វះអ្វី ។ ពួករាំរបាំសោតសឹងស្រស់ មិនទាបមិនខ្ពស់សឹងនារី ចេញដោយពួកបនដូចកិន្នរី សឹងស្រីជំទង់វង់ភ័ក្ត្រស្អាត ។ វង់ភ័ក្ត្រត្រចង់អង្គស្រឡះ ចង្កេះស្រៀវជ្រះពុំជួរជាតិ សក់វែងទង់ដែងបួងដោយខ្នាត ដោះក្បុំសម្អាតណែនឱរា សម្លេងចៀងជ្រួចដូចករវិក សើចលេងអឹកដូចសារិកា មុខគួរកាន់គិតស្និទ្ធស្នេហា នរណាយល់ហើយគួរអាល័យ ។ ស្រមៃហាក់ឃើញតែនៅមុខ យប់ព្រឹកជញ្ជឹងនឹងកែខៃ ប្រាថ្នារួមស្ថានប្រាណភិសម័យ ដោយក្ដីចេតនាថ្លៃសង្ឃា» (*វគ្គ ១៥១-១៥៤*) *។ កវីបានរំឭកប្រាប់ពីមហោស្រពឯទៀតៗ ដូចជា ៖ «កុំមេឌីបារាំងសេស* (Comédie-Française) *សល់សឹងល្អអស់កលឥតឧបមា នេះលេងតាមរឿងអតីតា នៅរឿងបច្ចុប្បន្នដែលកើតថ្មី* (*វគ្គ ១៥៥*) *។ មិនមានលោតរាំដូចល្ខោន លំទោនកែតែពាក្យសំដី ប្រៀបដូចបុរសប្រុសចង់ស្រី ស្រដីទៅមករកកាន់គ្នា* (*វគ្គ ១៥៦*) *។» ជាបញ្ចប់ កវីដើរតទៅទៀតតាមវិថី លោកក៏ពណ៌នាថា ៖* «មានផ្លូវដើរទៅយល់គ្រប់ល្បែង មូលាំងរូស (Moulin Rouge) ភ្លឺទែងសឹងង្វាលា នៅនោះមានស្រីល្អសោភា បើមានចេតនាឲ្យចូលទៅ ។ មានកន្លែងតែងជាស្ថានសួគ៌ម្ខាងតែងជានរកជ្រៅ (...) បារ [៥៥] ពុំមានខ្វះត្រង់ណា សន្និយាឃ្វាលាអុជភ្លឺទែង

---

(៥៥) មកពីពាក្យបារាំង (bar) គឺជាកន្លែងមានលក់គ្រឿងភេសជ្ជៈគ្រប់បែប, មានអាហារបរិភោគបាន ជួនកាល មានស្រីកំដរថែមទៀតទៅតាមសង្កាត់ ។

ទំនិញដាក់លក់មានដោយល្វែង មានគ្រប់ដំណែងដានមាគ៌ា (*វគ្គ ១៥៧-១៥៩*) ។»

*លោក សើន ដៀប មិនអាចអាក់ខានពីការចាប់អារម្មណ៍យ៉ាងខ្លាំងនឹង «រថទឹកក្រុតរត់ក្រោមដី»* (métro) ៖ «មានរថទឹកក្រុតរត់ច្រៀវច្រែ បើកបរក្នុងដីក្រោមគ្រឹហា កាត់ត្រង់តម្រង់ទីព្រឹក្សា នាមាហៅជាបិរវាំងសែន (Bois de Vincennes) ។ មានទីចំការច្បារឧទ្យាន ព្រឹក្សាយោនយានមានដោយដែន មនុស្សផងត្រសងរាប់សល់សែន ណែនណាន់ទៅកាន់ជាប្រក្រតី ។ មានទីកំពង់ទឹករងថ្លា នាវាសម្រាប់ជាអចិន្ត្រៃ មានស្បៀងជប់លៀងតែសព្វថ្ងៃ ទីព្រៃនាមនៃបិរបូរឡូញ (Bois de Boulogne) ។» *លោកបានទៅលេងកន្លែងវាលវង់ប្រណាំងសេះ ឃើញមានមនុស្សម្នាច្រើន, មានសេះ, រទេះសេះ ហើយនិងកន្លែងសម្រាប់អង្គុយមើលការប្រណាំងសេះនេះទៀត ។*

*រួមដោយខ្លី ចំពោះលោក សើន ដៀប ៖* «ប៉ារីសជាទីវិសេសសល់ ប្រៀបដូចមណ្ឌលកៃលាសស្ថាន អ្នកមានកុសលទើបទៅបាន ប្រាកដមិនមានភូតមុសា ។ ទៅសួគ៌និងបុណ្យកុសលជូន ទៅនេះឲ្យមានធួនទ្រព្យា ជំនួសជួសផលកុសលា អ្នកមានប្រាជ្ញាគួរយល់បាន» (*វគ្គ ១៦៦-១៦៧*) ។

## ទំនៀមទម្លាប់ប្រជាជនប៉ារីស

*យើងដឹងហើយថា គ្មានការធ្វើដំណើរមកក្រុងប៉ារីស ដោយពុំបានរៀបរាប់ពីការរស់នៅនិងទំនៀមទម្លាប់ប្រជាជននៅក្រុងនេះទេ ។ លោក សើន ដៀប បានកត់សម្គាល់ថា ៖*

« អ្នកស្រុកប៉ារីសចិត្តសុភាព សឹងល្អដរាបពុំរានកាន
ឃើញអ្នកបរទេសសឹងរាប់អាន ពុំមានមោហោចោរតិរ្ថិយ ។
បូរាណមានឈ្មោះហៅផរ៉ង់ ចិត្តត្រង់ពុំជួរជាតិអប្រិយ
មធុរសសោតស្នេះទាំងប្រុសស្រី ទាំងផែនដីបារាំងសេស ។
ឯថាមានមនុស្សចោរកំណាច អាចឆក់យកទ្រព្យអ្នកបរទេស
ទាំងនោះពុំមែនជាតិបារាំងសេស គឺអ្នកប្រទេសក្រៅទៅនៅ ។
យើងពុំបានថែងនៃនាមា ក្រែងមាននិន្ទាកើតហ្មងសៅ

ដល់អ្នកនគរប្រទេសក្រៅ　　ស្តីទៅបង្កើតជាទោសា ។
យើងថែងបន្តិចឲ្យតែដឹង　　គ្រាន់ជាដំណឹងសោះសង្កា
កុំឲ្យឆ្ងល់ឆ្ងាយខ្វាយចិន្តា　　ក្រែងថាបារាំងសេសចិត្តអាក្រក់ ។
ទាំងនេះគួរតែពិចារណា　　កុំឲ្យយកផ្កាថាជាលាមក
ទឹកថ្លាថាទៅជាទឹកល្អក់　　សុខទុក្ខគួរឲ្យពិចារណា ។ (៥៦) »
*(វគ្គ ១៦៨-១៧២) ។*

*ល្បើកនេះបញ្ចប់សេចក្ដីថា* «អញខ្ញុំថ្លាថ្លែងអធិប្បាយ បរិយាយសង្ខេបរឿង រដ្ឋា ប៉ារីសអសុដុង (?) (៥៧) ខ្ពង់សក្កា សូរេចស្រេចការម្ល៉េះឯងហោង» *(វគ្គ ១៧៣) ហើយលោក សើន ដៀប បានប្រគល់ល្បើកនេះទៅស្មៀនលោក ឲ្យចម្លងចប់នៅ ៨ កើត, ថ្ងៃសៅរ៍ ខែជេស្ឋ ឆ្នាំឆ្លូវត្រីស័ក នាវេលាម៉ោង ៥ ល្ងាច, រួចបានយកទៅបោះពុម្ពជាដំបូង នៅស្រុកឃ្លាំងក្នុងប្រទេសយៀកណាមសព្វថ្ងៃ ដូចមានសេចក្ដីបញ្ជាក់ស្រាប់ ៖*

« ខ្ញុំឲ្យស្មៀនខៀវក្រុំមអាឡាក្ខ　　ជាអ្នកស័សេររឿងខ្ញុំចង
សាចក្ដីសង្ខេបបែពទុំម្ទង　　ឲ្យតែជុនផោងយុលសាចក្ដី ។
ស័សេរចែងចបគ្រុបវោហា　　ក្នុងជេសមាស្សាទិនអ័ស្មី
ប្រែចេញហៅថាថ្ងៃប្រាំម្បី　　កេិតចូលសៅរីក្នុងឆ្នាំឆ្លូវ ។
ត្រីស័ក្ខ្យជាកចបគ្រុបប្រការ　　វេលាមោងប្រាំមល្ងាចត្រឹមត្រូវ
វេលាស្ងួស្តីខ្មីឥតសៅ　　ហេិ្យបោះពុំម្ភនៅស្រុកឃ្លាំង ។ (៥៨) »

---

(៥៦) សម្រង់អត្ថបទកំណាព្យ យើងបានកែទៅជាអក្ខរាវិរុទ្ធទំនើបហើយ ដើម្បី ម្យ៉ាងឲ្យអ្នកអានបានស្រួល ហើយម្យ៉ាងទៀត ដើម្បីចៀសវាងធ្វើកំណត់ក្រោមទំព័រច្រើនពេក នាំឲ្យអត្ថបទសិក្សានេះ កាន់តែវែងទៅទៀត ។

(៥៧) ឧដុង្គ (?) ។

(៥៨) កែតាមអក្ខរាវិរុទ្ធទំនើប ៖

« ខ្ញុំឲ្យស្មៀនខៀវក្រុមអាល័ក្ស　　ជាអ្នកសរសេររឿងខ្ញុំចង
សេចក្ដីសង្ខេបបែបទំនង　　ឲ្យតែជនផងយល់សេចក្ដី ។
សរសេរថែងចប់គ្រប់វោហារ　　ក្នុងជេស្ឋមាសាទិនអដ្ឋី
ប្រែចេញហៅថាថ្ងៃប្រាំបី　　កើតចូលសៅរ៍ក្នុងឆ្នាំឆ្លូវ ។

*(វគ្គ ១៧៥-១៧៦) អក្ខរាវិរុទ្ធដើម ។*

## ការប្រមើលមើលរបស់មន្ត្រី – ប្រតិភូ

*ប្រសិនបើលោក សើន ដៀប ចង់ក្រងកំណាព្យ «ដំណើរទៅប្រទេសបារាំងក្នុងឱកាសពិព័រណ៍ពិភពលោក» នេះ ដោយចេញពីចិត្តផ្ទាល់ គឺពិតជាលោកបានធ្វើការត្រួតពិនិត្យប្រុងប្រយ័ត្ន ក្នុងសតិអារម្មណ៍ផ្ទាល់ខ្លួន ដោយចេតនាឬក៏គ្មាន ព្រោះយើងឃើញកំណាព្យនេះបានបោះពុម្ពផ្សាយនៅកម្ពុជា បន្ទាប់ពីលោកបានត្រឡប់ចូលមកស្រុកវិញ ដោយឥតមានទទួលផលវិបាកអ្វីពីអាជ្ញាធរបារាំងសោះ ។ រដ្ឋបាលអាណាព្យាបាលបារាំង គឺពិតជាចង់ដឹងពីចំណាប់អារម្មណ៍របស់មន្ត្រីប្រតិភូនេះមិនខានឡើយ ។ នេះបញ្ជាក់ពីទំនាក់ទំនងមានសារៈសំខាន់ ក្នុងករណីដែលពត៌មាននេះចេញពីការប្រមើលមើលរបស់មន្ត្រីជាន់ខ្ពស់ម្នាក់ ដែលមានចំណេះដឹងបែបបស្ចិមប្រទេស បានចេញដំណើរពីប្រទេសខ្លួន ឃើញពិភពក្រៅ ហើយជាពិសេស គឺជាពត៌មានដែលកវីនិពន្ធនេះចង់ផ្តល់ឲ្យប្រជាជនខ្លួនយល់ដឹងផង ។*

*តាមការពិត ទំនាក់ទំនងនេះមានរចនាសម្ព័ន្ធល្អណាស់ ។ កវីបានរំឭកបន្ថែមរឿងនិទានខ្លីៗ គាប់ចិត្ត បញ្ចូលខាងនេះបន្តិច ខាងនោះបន្តិច ក្នុង «សំណេរ» របស់លោក ស្តីពីប្រជាជាតិនានា ដែលលោកបានជួបប្រទះតាមផ្លូវដំណើរលោក, ជួនកាល កវីបានផ្តល់ពត៌មានជាច្រើនលើទំនៀមទម្លាប់ដូចជា នៅក្នុងករណីជនជាតិជ្វា ដែលលោកបានឃើញជាបឋមនៅសិង្ហបុរី ហើយជ្វានៅទីនោះ មានការរស់នៅដូចអ្នកស្រុកនៅកម្ពុជា និងដូចប្រជាជាតិម៉ាដាកាស្ការ ដែលលោកឃើញនៅពិព័រណ៍ពិភពលោកដោយឥតឲ្យយោបល់បញ្ជាក់ទេ ។ យើងសង្កេតឃើញដែរថា លោក សើន ដៀប បានយកចិត្តទុកដាក់កត់សម្គាល់ពីមេរៀនប្រវត្តិសាស្ត្រប្រទេសជ្វា, ស្រីលង្កា និងម៉ាដាកាស្ការ (លោកយល់ឃើញតាមការប្រមើលមើលនៃជនជាតិបារាំង) បានរញ្ជួយផ្លាស់ប្តូរ ដោយការលុកលុយចូលភ្លាមៗ នៃជនជាតិអឺរ៉ុប ។ ការពោលបញ្ជិត*

---

ត្រើសកជាក់ចប់គ្រប់ប្រការ | វេលាម៉ោងប្រាំល្ងាចត្រឹមត្រូវ
វេលាសួស្តីខ្មីឥតសៅ | ហើយ(បាន)បោះពុម្ពនៅស្រុកឃ្លាំង ។»

បញ្ចៀងពីភាពបាត់បង់ឯករាជ្យនៃជនជាតិខាងលើនេះ នឹងអាចនាំឲ្យអ្នកអានអត្ថបទល្បើកលោក មិនព្រងើយកន្តើយ ដោយឃើញថា ជនជាតិខ្មែរយើងក៏បានរស់នៅក្នុងការពិសោធន៍នេះ នាបីឬបួនទសវត្សមុននេះ ។ លោក សើន ដៀប បានពង្រីងបន្ថែមដោយរំឭកពី «ព្រេងវាសនា» នៃជនជាតិទាំងនេះ ដោយបង្ហាញពីវត្តមាននៃជនជាតិអឺរ៉ុបនៅក្នុងទីកំពង់ផែធំ ៗ ដែលមាននាវាសំចតនៅ ។ ចំពោះសិង្ហបុរី គឺជាស្រុកទី ១ ដែលលោកបានទស្សនាបន្ទាប់ពីព្រៃនគរ, លោកបានកត់សម្គាល់ឃើញថា ពួកអង់គ្លេសមានកម្លាំងទ័ពខ្លាំងក្លា ហើយនៅលើភ្នំ ពួកអង់គ្លេសយាមឃ្លាំមើលឆកសមុទ្រ ។

លោក សើន ដៀប និទានសង្កត់ទៅលើបាតុភូតតំបន់ក្រុងបែបបស្ចិម-ប្រទេស ដោយកត់សម្គាល់ពាសពេញ រំឭកពីទិដ្ឋភាពធំសម្បើមនៃគ្រឹហាពីថ្មជាច្រើនជាន់ថ្នាក់, ផ្លូវខ្វាត់ខ្វែង, ចរាចរណ៍ណែនណាន់តាន់តាប់, ភាពសំខាន់នៃចលនាពាណិជ្ជកម្មខ្លាំងក្លា និងវត្តមានពាណិជ្ជករអឺរ៉ុប ហើយលោកនិទានខ្លះ ៗ ពីជោគវាសនាប្រទេសកម្ពុជា ដែលមិនសូវខុសពីប្រទេសអាស៊ីនានា ដែលលោកបានឃើញដែរ ។ ក្នុងករណីស្រុក «អាដែន» ករីបានរំឭកបង្ហាញពី «ជីវិតលំបាកខ្លាំងក្លារបស់ប្រជាជន», តែលោកពន្យល់បន្ថែមពីស្ថានភាពធាតុអាកាស ។ ចេញពីតំបន់ក្តៅ លោក សើន ដៀប មានការចាប់អារម្មណ៍យ៉ាងខ្លាំងលើការរីងស្ងួត, ដីបែកក្រហែង និងកំដៅក្តៅហែងគ្របសង្កត់ ។

ឥតមានពេលណាមួយ លោកពុំបាននិទានបញ្ចិតបញ្ចៀងទៅលើជំនឿសាសនា ក្រៅពីស្រីលង្កា ព្រោះលោកសប្បាយរីករាយ ដោយបានមកដល់ប្រទេស ដែលប្រជាជនស្រុកនេះមានជំនឿដូចលោក ហើយជាទីកន្លែងដែលមានចេតិយបញ្ចុះសារីរិកធាតុព្រះសម្មាសម្ពុទ្ធ តែហាក់ដូចជាលោកមិនបានចូលជ្រៅទៅក្នុងស្រុកនេះទេ គឺនៅកណ្ឌី ដែលជាទីកន្លែងដែលគេរក្សាព្រះចេតិយ ។

បន្ទាប់ពីបានរំឭកបញ្ចាំងពីជនជាតិនានារួចហើយ លោក សើន ដៀប បានជ្រើសរើសនិងបង្ហាញប្រទេសបារាំងហាក់ដូចជាស្ថានសួគ៌, កន្លែងទេព្ធា ដោយល្បងពណ៌នាការពិតជាក់ស្តែង និងតាមអារម្មណ៍ស្រមើស្រមៃ គឺលោកប្រៀប

ធៀបទៅនឹងទេវលោក ដែលប្រជាជនខ្មែរធ្លាប់យល់ដឹង ។ សំណេរពោលសរសើរនេះ លោក សើន ដៀប បង្ហាញបញ្ចេញមកដោយចេតនាពីប្រទេសបារាំងជាមហាអំណាចខ្ពង់ខ្ពស់ទាំងផ្នែកសេដ្ឋកិច្ច, បច្ចេកទេសនិងវប្បធម៌ ។ នៅទីបញ្ចប់ លោកធ្វើការបំភ្លឺដោយធ្វើតារាងបញ្ចើចបញ្ចើលើកដើងយ៉ាងខ្លាំង ពីទំនៀមទម្លាប់និងសីលធម៌នៃជនជាតិបារាំងសេស ។

ដោយប៉ិនប្រសប់ លោក សើន ដៀប បញ្ជាក់ប្រាប់ថា ពិភពអស្ចារ្យនេះមិនមែនសម្រាប់ទុកតែចំពោះតែជនជាតិអឺរ៉ុបទេ ។ ជនបរទេស ដូចជា ជនជាតិខ្មែរយើង ដែលមាន « បុណ្យ » (គួរតែយល់ឲ្យលើសឆ្ងាយចេញពីទស្សនៈពុទ្ធនិយម) គឺដោយបានខំសិក្សារៀនសូត្រភាសាបារាំង និងទទួលចំណេះដឹងវប្បធម៌អឺរ៉ុបនោះអាចនឹងបានមកដល់ពិភពនេះដែរ ហើយនឹងអាចទទួលស្គាល់ស្មើភាពគ្នាជាមួយពួកបារាំងសេសបាន ។ លោក សើន ដៀប បញ្ជាក់ប្រាប់អ្នកអានទៀតថា កាលស្នាក់នៅក្រុងប៉ារីស លោកសំណាក់ក្នុងសង្កាត់ដែលមានតែអភិជននិងអ្នកមានស្តុកស្តម្ភ ។ នេះហើយជាសារៈសំខាន់របស់លោកចំពោះអ្នកអានខ្មែរយើង ។

« ល្បើកលើកតាមផ្លូវទៅស្រុកបារាំងសេសនៅទីតាំងតុនៅក្រុងប៉ារីស » នេះអ្នកអានអាចយល់ដឹងបានស្រួល ព្រោះអត្តរូបកំណាព្យនេះ ស្ថាបនាឡើងដើម្បីដាស់អារម្មណ៍អ្នកអាន ដែលធ្លាប់អានសាស្ត្រាល្បែង រមែងមានការពណ៌នាតាមភាសាកាព្យឃ្លោង ពីការរញ្ជួយចិត្ត ដោយឃើញធម្មជាតិ, សមុទ្រ, សូររលកបោកបក់, ខ្យល់ជាដើម... ។ ហេតុនេះហើយ តាមរយៈកំណាព្យនេះ, ពិភពបរទេសអាចហូរចូលដោយរលូន ក្នុងពិភពខ្មែរឲ្យផ្សំទៅជាធាតុមួយគត់ ។

## សេចក្តីបញ្ចប់

ជាប្រាកដ គេស្គាល់ដោយមិនដឹងថាពីការទទួលយករាប់អានប្រភេទអក្សរសិល្ប៍ « និរាស » នេះ ដល់កម្រឹតណាទេ ។ តែក្នុងរយៈពេល ២០ ឆ្នាំបន្ទាប់

ក្រោយមក មានដំណើរជាផ្លូវការមួយទៀតមកប្រទេសបារាំង[៥៩] ហើយដំណើរនេះបានចាប់បដិសន្ធិស្នាដៃអក្សរសិល្ប៍ ជាអត្ថបទកំណាព្យ មានទម្រង់ដូចគ្នានឹងល្បើកលោក សើន ដៀប ដែរ ។ ដូចនេះ នាំឲ្យគេគិតយល់និងសន្និដ្ឋានថា ប្រភេទអក្សរសិល្ប៍ពិសេសនេះ បានពង្រឹងជំហរចាប់ពីពេលនោះមក ។ កវីនិពន្ធទាំងពីរនេះ មិនមាននៅក្នុងស្ថានភាពដូចគ្នាទេ ។ ដោយម្យ៉ាង នៅចន្លោះពេលនោះ ស្ថានការណ៍នយោបាយមានការផ្លាស់ប្តូរ ហើយ ម្យ៉ាងទៀត លក្ខន្តិកៈសង្គមកវីនិពន្ធទាំងពីរ មិនដូចគ្នា ។ ពិតមែនតែអ្នកទាំងពីរជាប្រតិភូរបស់ព្រះមហាក្សត្រ, លោកឧកញ៉ា អ៊ុក មានឋានានុក្រមជាអគ្គរាជទូត ។ លោកមកប្រទេសបារាំងជាលើកទី ២[៦០] ហើយលោកស្គាល់រដ្ឋអំណាចបារាំងច្បាស់លាស់ ហើយលោកមានបុត្រាពីរទុកឲ្យសិក្សានៅក្នុងសាលាធំល្អប្រសើរ ៗ នៅអឺរ៉ុប ។ គេពុំឃើញក្នុងអត្ថបទនិរាសលោកស្តីពីការភ្ញាក់ផ្អើល នឹងភាពអស្ចារ្យបែបល្ងង់ខ្លៅរបស់លោក សើន ដៀប ទេ ។ ឧកញ៉ា អ៊ុក អធិប្បាយពណ៌នាតិចណាស់, តែលោកសង្កត់ទៅលើជំនួបនានាជាមួយអ្នកមុខអ្នកការ និងពិធីការផ្សេង ៗ ។ លោកឧកញ៉ា អ៊ុក កត់ត្រាដោយយកចិត្តទុកដាក់ ដូចជា ពេលដែលលោកបានជួបអធិរាជ ខៃឌិញ (Khai Dinh)[៦១] គឺលោកបានគំនាប់តាមទម្លាប់បារាំងសេស គឺលោកបានចាប់

---

(៥៩) ព្រះករុណាព្រះចាឧសម្តេចព្រះ ស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី ព្រះរាជដំណើរទៅក្រុងបារាំងសែស ឆ្នាំមមីអដ្ឋស័ក ត្រូវនឹងឆ្នាំបារាំង ១៩០៦ ។ និពន្ធដោយអ្នកឧកញ៉ាវាំងវរៈវៀងជ័យ អធិបតីពិភ័ក្តិស្រីង្គារ ឧត្តមក្រុមពាហុ ជួន, បោះពុម្ពដោយ មីស្ហែល ឬទ្ធី អង់តែល្ម និង អូលីវិយេរ៍ ដឺ ប៊ែរណុង, ភ្នំពេញ, ២០០៦, ១៨៩ ទំព័រ ។ នេះជាអត្ថបទសម្រាយ យើងមិនបញ្ចូលក្នុងប្រភេទ « និរាស » ទេ ។ សូមអានកំណត់លេខ ៤ ។

(៦០) សូមអាន ព្រះករុណាព្រះចាឧសម្តេចព្រះ ស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី ព្រះរាជដំណើរទៅក្រុងបារាំងសែស ឆ្នាំមមីអដ្ឋស័ក ត្រូវនឹងឆ្នាំបារាំង ១៩០៦ ។ ទំព័រ ៩ ៖ លោកមានងារជា « ឧកញ៉ាប្រើជាសោភ័ណ (អ៊ុក) ស្មៀនប្រែភាសាថ្វាយ » បានមកតាមដង្ហែហ្លួង ស៊ីសុវត្ថិ មកប្រទេសបារាំង នាឆ្នាំ ១៩០៦ ។

(៦១) Selon Nguyên Thê Anh (*Monarchie et fait colonial au Viêt-Nam (1875–1925). Le crépuscule d'un ordre traditionnel*, Paris, L'Harmattan, 1992, p. 253), c'est Pasquier qui entreprit de convaincre Khai Dinh d'efffectuer un voyage en France et d'y conduire son fils unique « pour le remettre entre les mains du gou-

ព្រះហស្តព្រះចៅអធិរាជ, បានសេចក្តីថា លោកមិនលុតក្រាបបង្គំដូចលោកគោរពវន្ទាព្រះមហាក្សត្រខ្មែរឡើយ ។ គេឃើញក្នុងទីនេះពីភាពសំខាន់ដោយយោងទៅលើឋានានុក្រមនិងនយោបាយបារាំងក្នុងការស្ថាបនា « ទំនាក់ទំនងបែបថ្មី» រវាងប្រទេសនានានៅឥណ្ឌូចិន ។ កវីនិពន្ធយើងទាំងពីរ បានសង្កត់ព្រមគ្នាទៅលើការវាយតម្លៃតួនាទីប្រទេសបារាំង ក្នុងកម្ពុជរដ្ឋ ដោយឥតសើរើឬចោទបញ្ហាផ្សេង ៗ ទេ ។ ក្រៅពីនេះទៀត, ឧកញ៉ា អ៊ុក បាននាំពាំយកសំដីលោក ម៉ូរីស ឡុង (Maurice Long) ជាអតីតទេសាភិបាលឥណ្ឌូចិន (១៩២០-១៩២២) សរសើរពីឥរិយាបថនិងវីរភាពហ្លួង ស៊ីសុវត្ថិ នាឆ្នាំ ១៨៧៦ ដោយបានបង្ក្រាបការបះបោរចលាចលនៅកម្ពុជា ។ ការបោះពុម្ពផ្សាយ, ក្នុងចន្លោះពេល ២០ ឆ្នាំ, អត្ថបទកំណាព្យដើម្បីរំឭកពីដំណើរផ្លូវការអញ្ជើញដោយរដ្ឋអំណាចបារាំងនេះ បង្ហាញឲ្យឃើញថា អាជ្ញាធរបារាំងបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីការឃោសនានយោបាយអាណានិគម ៕

---

vernement français, en lui demandant de veiller à son intruction et son éducation ». Sur les effets positifs (sur l'empereur qui eut une véritable révélation du retard de son pays) et négatifs de ce voyage (réactions des Viêtnamiens de France tel Phan Chu Trinh qui écrivit des articles violents dans la presse), voir Nguyên Thê Anh, 1992, p. 254–255 ៕



ផែនទីដំណើរលោក សើន ដៀប ពីព្រៃនគរទៅដល់ម៉ារសី តាមផ្លូវសមុទ្រ ។



រូបពីឆ្វេងទៅស្ដាំ ៖ ឧកញ៉ា កុល ដឺម៉ុងតេរោ, ឧកញ៉ាវាំង ជួន និង ឧកញ៉ា សើន ដៀប
ដង្ហៃហ្លួង ស៊ីសុវត្ថិ មកធ្វើទស្សនកិច្ចប្រទេសបារាំងនាឆ្នាំ ១៩០៦
(រូបស្រង់ចេញពីបណ្ណសារជាតិភ្នំពេញ) ។